**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

-សំណុំរឿងព្រហ្មទណ្ឌលេខ ៤៤៤
ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០
-ជំនុំជម្រះលេខ ១១០៦
ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១០
-សាលក្រមព្រហ្មទណ្ឌ
លេខ ១០៥ ក្រ១
ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០

# **សាលក្រមប្រជារាស្ត្រខ្មែរ**

## **សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការនៃសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១០ ដោយមានសមាសភាពជំនុំជម្រះដូចតទៅ :

### **<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

| | | |
|---|---|---|
| លោក | **កែ សាខន** | អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សា |
| លោកស្រី | **ចាំង ស៊ុនណាត** | ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា |
| លោក | **ជា សុខឡេង** | ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា |

### **<u>តំណាងអយ្យការ</u>**

| | | |
|---|---|---|
| លោក | **សុខ កឿន** | ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ |

### **<u>ក្រឡាបញ្ជីសវនាការ</u>**

| | | |
|---|---|---|
| លោក | **សុខ នី** | ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ |

### **ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៤៤ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដែលមាន :

**-ជនជាប់ចោទឈ្មោះ សម រង្ស៊ី ភេទ ប្រុស អាយុ ៦០ឆ្នាំ ជាតិ ខ្មែរ មុខរបរ តំណាងរាស្ត្រ** មណ្ឌលកំពង់ចាម និងជាប្រធានគណបក្ស សម រង្ស៊ី កើតនៅសង្កាត់លេខ២ ក្រុងភ្នំពេញ ទីលំនៅសព្វថ្ងៃផ្ទះលេខ៥៧៦ ផ្លូវជាតិលេខ២ ក្រុមទី៣១ ភូមិព្រែកតាគង់ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ សម សារី ម្តាយឈ្មោះ អ៊ិន អែម ប្រពន្ធឈ្មោះ ជូឡុង សូមូរ៉ា មានកូន ០៣ នាក់

**គេចខ្លួនដោយមានដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៣១២ គព្រ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ ២០១០។**

លោក **ជុង ជូងី** ជាមេធាវីការពារឱ្យជនជាប់ចោទ

ជាប់ចោទពីបទ **ការក្លែងបន្លំអក្សរក្នុងឯកសារសាធារណៈ និងការផ្សាយព័ត៌មានមិនពិត** ប្រព្រឹត្តនៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា កាលពីខែកុម្ភៈ ឆ្នាំ២០១០ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៩ និងមាត្រា ៦២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល

អាស័យដ្ឋាន: អាគារលេខ ៦៣ ផ្លូវលេខ ២០៥ -៣៤៨ សង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌ ចំការមន, ភ្នំពេញ ទូរសារ-ទូរស័ព្ទ: (៨៥៥)-២៣ ២១០ ៦០១/២៣ ២១០ ៦០២
Adress : #63, Street 205-348, Sangkat Tuol Svayprey2, Khan Chamkar mom, Phnom Penh, Cambodia. Fax-Phone : (855)-23 210 601 / 23 210 602

-**ដើមបណ្តឹងរដ្ឋប្បវេណី** : រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា តំណាងដោយលោក មេធាវី **គី តិច** តាមលិខិតប្រទានសិទ្ធិលេខ ៣២.សប្រទ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

-**បានឃើញ** ពាក្យបណ្តឹងលេខ ០០១ អ.ក.ប.ច/ម.ធ.រ.ប ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ របស់លោកមេធាវី **គី តិច** មេធាវីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

-**បានឃើញ** លិខិតប្រទានសិទ្ធិលេខ ៣២.សប្រទ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ១០៧១ អ.យ.ខ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១០ របស់លោក **សុខ រឿន** ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ១១៥០ ដ.ជ.រ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០ របស់លោក **អឿង សៀង** ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** ដីកាកោះហៅជនជាប់ចោទឱ្យចូលរួមសវនាការ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

**អង្គហេតុនៃរឿងមានដូចតទៅ:**

កាលពីខែកុម្ភៈ ឆ្នាំ២០១០ លោក សម រង្ស៊ី បានធ្វើការសំភាសន៍ជាសម្លេងផ្ទាល់ និងបានបង្ហាញនូវរូបភាព ឯកសារក្លែងបន្លំដូចជា រូបថតផែនទី ខ្សែបន្ទាត់ព្រំដែនព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីយកមកប្រើប្រាស់បង្ហាញ ពន្យល់ជាអក្សរ ជាលេខ ជាច្រើនទំព័រ ហើយផ្សព្វផ្សាយតាមប្រព័ន្ធ INTERNET ក្នុងគោលបំណងបំភាន់មតិជាតិ និងអន្តរជាតិឱ្យយល់ខុសលើការងាររបស់គណៈកម្មការចម្រុះទទួលបន្ទុកកិច្ចការព្រំដែនកម្ពុជា-វៀតណាម ធ្វើឱ្យប៉ះពាល់ដល់ស្ថេរភាព និងសន្តិសុខជាតិ នេះជាចេតនាទុច្ចរិតក្នុងការក្លែងបន្លំឯកសារសាធារណៈ និងប្រើប្រាស់ឯកសារក្លែងបន្លំ ដើម្បីផ្សាយព័ត៌មានមិនពិត ក្នុងបំណងបំភាន់ព័ត៌មានទម្លាក់កំហុសដោយអសុទ្ធចិត្តមកលើរាជរដ្ឋាភិបាលកម្ពុជា ។

## <u>នាពេលសវនាការ</u>

-ក្រឡាបញ្ជីអានដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៣១២ តព្រ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១០ ចេញដោយចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

-ក្រឡាបញ្ជីអានពាក្យបណ្តឹងរបស់ជនជាប់ចោទឈ្មោះ **សម រង្ស៊ី** តាមលិខិតចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១០ ថា :

១-ការចោទប្រកាន់ : ផែនទី SGI ខ្នាត ១/១០០.០០០ ដែលបានតម្កល់នៅអង្គការសហប្រជាជាតិឆ្នាំ១៩៦៤ និងផែនទីឧបសម្ព័ន្ធអមសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ ពុំមានក្រឡាការ៉ូនៅលើសន្លឹកផែនទីដូចផែនទីដែលលោក សម រង្ស៊ី បានបង្ហាញ និងផ្សព្វផ្សាយនោះទេ

**សេចក្ដីបំភ្លឺ** : នេះពិតជាពាក្យចោទប្រកាន់យ៉ាងចម្លែក ។ នៅលើផែនទីទាំងអស់សុទ្ធតែមានក្រឡាការ៉ូដែលគេហៅថា graticule។ Graticule គឺជាបណ្ដាញខ្សែរយៈស្រប (Parallèle) និងខ្សែរយៈទទឹង (Méridien) ដែលមានចន្លោះស្មើគ្នានៃរយៈទទឹង និងរយៈបណ្ដោយ នៅលើផ្ទៃផែនដី។ ទាំងផែនទី SGI ផ្លូវការឆ្នាំ ១៩៥២ ក្នុងសម័យបារាំង ដែលមានខ្នាត ១/១០០.០០០ និងផែនទីកងទ័ពអាមេរិកឆ្នាំ ១៩៦៦ ដែលមានខ្នាត ១/៥០.០០០ សុទ្ធតែមានក្រឡាការ៉ូ graticule ដូចគ្នា សូមមើលរបាយការណ៍របស់លោកសាស្ត្រាចារ្យ Régis Caloz ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ ទំព័រទី ៧ បង្ហាញពី "ការត្រួតស៊ីគ្នានៃការបែងក្រឡាការ៉ូ graticule"។ មួយក្រឡាការ៉ូៗ នៅលើផែនទីទាំងពីរ គឺស្មើនឹងប្រវែង ១ គីឡូម៉ែត្រនៅលើផែនដី ។

២-ការចោទប្រកាន់ : លោក សម រង្ស៊ី បានផលិតផែនទីថ្មីមួយ ដោយមានកំណត់ទីតាំងបង្គោលព្រំដែនខុសពីទីតាំងបង្គោលព្រំដែន ដែលក្រុមបច្ចេកទេសចម្រុះកិច្ចការព្រំដែនបានកំណត់នៅក្នុងផែនទី ។

**សេចក្ដីបំភ្លឺ** : ខ្ញុំមិនដែលបាន "បង្កើតផែនទីថ្មី" ណាមួយទេ ។ ខ្ញុំគ្រាន់តែបង្ហាញផែនទីទាំងពីរខាងលើដែលមានស្រាប់ប៉ុណ្ណោះ ។ ខ្ញុំក៏មិនដែលបានកំណត់ទីតាំងបង្គោលព្រំដែនអ្វីណាមួយទេ ។ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៩ អ្នកភូមិមួយក្រុមនៅមូលដ្ឋានបានអញ្ជើញខ្ញុំទៅពិនិត្យមើលរបស់ដែលហៅថា " តំរុយបង្គោលព្រំដែនលេខ ១៨៥ " ដែលខ្ញុំបានដក ដោយហេតុថា ម្ចាស់កម្មសិទ្ធិដីធ្លីនៅទីនោះបានតវ៉ាថា របស់ដែលហៅថា" តំរុយបង្គោលព្រំដែន ត្រូវបានបោះនៅលើដីស្រែដែលជាកេរ្តិ៍ដំណែលពីដូនតារបស់គាត់។

ទីតាំងតំរុយបង្គោលព្រំដែន ៣ ផ្សេងទៀត ដែលនៅជិតនោះដែរ គឺតំរុយបង្គោលព្រំដែនលេខ ១៨៤ ១៨៦ និង ១៨៧ អ្នកភូមិដែលមានការភ័យខ្លាចពីការបាត់បង់ដីស្រែរបស់ពួកគាត់ដោយសារការរំលោភឈ្លានពានព្រំដែនពីប្រទេសវៀតណាម បានបង្ហាញដល់សមាជិកសភាគណបក្សប្រឆាំងផងដែរ។ ក្រោយពីបានវាស់និយាមការទីតាំងតំរុយបង្គោលព្រំដែនដែលបានបោះ ខ្ញុំបានស្នើឱ្យអ្នកជំនាញវិជ្ជាជីវៈខាងផែនទី ដៅចំណុចតម្រុយបង្គោលព្រំដែនទាំង ៤ នៅលើផែនទីទាំងពីរខាងលើឱ្យបានជាក់លាក់ ស្របតាមនិយាមការភូមិសាស្ត្រពិតប្រាកដ (សូមមើលរបាយការណ៍របស់លោកសាស្ត្រាចារ្យ Régis Caloz នៅទំព័រទី ១០ បន្ទាត់ទី ១២ បានបង្ហាញពីការកំណត់ទិសដៅនៃទីតាំងទាំង ៤ ក្នុងតំបន់ព្រំដែន) ។

ឥឡូវនេះយើងមានសេចក្ដីសប្បាយរីករាយ ដោយបានដឹងថា ទីតាំង "ពិតប្រាកដ" នៃតម្រុយបង្គោលព្រំដែនលេខ ១៨៤ ១៨៥ ១៨៦ និង ១៨៧ ដែលគណៈកម្មាធិការជំនាញកិច្ចការព្រំដែនចម្រុះ "កម្ពុជា-វៀតណាម" បានកំណត់នាពេលបច្ចុប្បន្ននេះ គឺស្ថិតនៅក្នុងទឹកដីខ្មែរចម្ងាយ ៥៧០ ម៉ែត្រ ៥១៦ ម៉ែត្រ ៧២០ ម៉ែត្រ និង ៥១០ ម៉ែត្រពីបន្ទាត់ព្រំដែន (សូមពិនិត្យមើលការ

ពន្យល់ ដោយមានការលើកយកផែនទី ដែលគណៈកម្មាធិការព្រំដែនរបស់រដ្ឋាភិបាលបានបង្ហាញនៅចំពោះតុលាការ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១០) ។

៣-ការចោទប្រកាន់ : ប្រើប្រាស់និយាមការទីតាំងបង្គោលព្រំដែន ដោយប្រើប្រាស់បច្ចេកទេសមិនត្រឹមត្រូវ គឺយកនិយាមការទីតាំងបង្គោលព្រំដែនវាស់វែងដោយឧបករណ៍ GPS ដោយប្រើទិន្នន័យយោង (Datum) WGS 84 មកដាក់លើផែនទី ដែលមានទិន្នន័យយោង Indian 1960 (Datum Indian 1960) តាមធម្មតាការកំណត់ទីតាំងណាមួយនៅលើផែនទី ទាល់តែចំណុចទីតាំងនោះមាននិយាមការ ដែលមានទិន្នន័យយោង (Datum) ដូចគ្នា ។

**សេចក្តីបំភ្លឺ** : ប្រើប្រាស់និយាមការ ដែលមានទិន្នន័យយោង (Datum WGS 84 vs. Datum Indian 1960) មិនដូចគ្នា គឺជាកំហុសខាងទ្រឹស្តី ប៉ុន្តែក្នុងករណីនេះ ចុងបញ្ចប់វាមិនប៉ះពាល់លទ្ធផលទេ ។ ករណីនេះមានការពន្យល់យ៉ាងច្បាស់នៅក្នុងរបាយការណ៍របស់លោកសាស្ត្រាចារ្យ Régis Caloz (នៅទំព័រទី ១០) ។ លោកសាស្ត្រាចារ្យ Régis Caloz បានបង្ហាញថា និយាមការទីតាំងដែលស្រង់មកពីឧបករណ៍ GPS ប្រើទិន្នន័យ (Datum) WGS 84 និងនិយាមការទីតាំងដែលប្រើទិន្នន័យ (Datum) Indian 1960 មានលទ្ធផលត្រូវគ្នា ។

៤-ការចោទប្រកាន់ : ប្រើប្រាស់និយាមការទីតាំងបង្គោលព្រំដែនលេខ ១៨៦ ក្នុងពេលដែលក្រុមបច្ចេកទេសចម្រុះកិច្ចការព្រំដែននៃប្រទេសទាំងពីរកម្ពុជា-វៀតណាម ពុំបានកំណត់នៅលើដីនៅឡើយ ។

**សេចក្តីបំភ្លឺ** : ដូចដែលយើងបានប្រកាសរួចមកហើយ ទីតាំងរបស់ដែលហៅថា តម្រុយបង្គោលព្រំដែនបណ្តោះអាសន្នលេខ ១៨៤ ១៨៥ ១៨៦ និង ១៨៧ ក្នុងស្រុកចន្ទ្រា ខេត្តស្វាយរៀង ត្រូវបានអ្នកភូមិ និងប្រជាកសិករខ្មែរ ដែលជាអ្នករងគ្រោះដោយសារការរីបអូសយកដីស្រែរួមជាមួយនឹងការរំលោភព្រំដែនផងនោះ បានចង្អុលបង្ហាញដល់សមាជិករដ្ឋសភា និងសមាជិកក្រុមប្រឹក្សាដែលជាប់ឆ្នោតរបស់គណបក្ស សម រង្ស៊ី ។ និយាមការភូមិសាស្ត្រពាក់ព័ន្ធ ដែលមាននៅលើដី គឺយើងទទួលបានដោយមានជំនួយពីឧបករណ៍ GPS ។

-លោក **តី តិច** មេធាវីតំណាងរាជរដ្ឋាភិបាលជាដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា : កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ ខ្លួនបានដាក់ពាក្យបណ្តឹងមកសាលាដំបូងរាជធានីភ្នំពេញ ប្តឹងពីឈ្មោះ សម រង្ស៊ី ពីបទ ក្លែងលិខិតសាធារណៈ និងផ្សព្វផ្សាយព័ត៌មានមិនពិត ប្រព្រឹត្តកាលពីខែកុម្ភៈ ឆ្នាំ២០១០ ដោយឈ្មោះ សម រង្ស៊ី បានធ្វើការសំភាសន៍ប៉ះពាល់ព្រំដែនកម្ពុជា-វៀតណាមគឺ ទី១ ផែនទី SGI ១/១០០ ០០០ ឆ្នាំ១៩៦៤ និងផែនទីឆ្នាំ២០០៥ របស់កម្ពុជាពុំមានក្រឡាការ៉ូដូចដែលលោក សម រង្ស៊ី បានផ្សព្វផ្សាយនោះទេ ។ ទី២ លោក សម រង្ស៊ី បានដាក់បង្គោលព្រំដែនថ្មីខុស ។ ទី៣ : ប្រើនិយាមការ GPS WGS-84 ដាក់លើផែនទី Indian 1960 ដោយពុំបំលែងទិន្នន័យ ហើយប្រើនិយាមការខុស ។ ភស្តុតាងមានឯកសារដែលខ្លួនបានដាក់ជូនក្នុងសំណុំរឿងស្រាប់មានជា

ឯកសារចំនួន ២៦សន្លឹក សាក្សី និងសំដីរបស់លោក សម រង្ស៊ី ដែលមានក្នុង CD ហើយលោក សម រង្ស៊ី ក៏បានទទួលស្គាល់សំលេងនោះថា ជាសំលេងរបស់គាត់ ហើយដែលសំលេងនោះបានផ្សាយទូទាំងពិភពលោក ។ ខ្លួនយល់ឃើញថា ពុំមានភាពចាំបាច់ក្នុងការលើកយកភស្តុតាងមកបង្ហាញម្តងមួយៗ តាមសំណើរបស់មេធាវីការពារជនជាប់ចោទទេ ព្រោះភស្តុតាងទាំងនោះបានដាក់ចូលក្នុងសំណុំរឿងស្រាប់ហើយ ហើយលោកមេធាវីការពារជនជាប់ចោទប្រហែលជាបានថតចម្លងហើយ តែបើពុំទាន់បានថតចម្លងជាបញ្ហារបស់គាត់ក្នុងនាមជាមេធាវីការពារជនជាប់ចោទប៉ុណ្ណោះ។ តុលាការអាចពិនិត្យភស្តុតាងដែលខ្លួនបានដាក់ជូននេះជាមុនហើយ ពុំចាំបាច់យកមកម្តងមួយៗ នាំឱ្យខាតពេលវេលានោះទេ ។ សំណូមពរផ្តន្ទាទោស លោក សម រង្ស៊ី តាមច្បាប់ និងទាមទារសំណងជម្ងឺចិត្តចំនួន ១០០ ០០០ ០០០ រៀល ( មួយរយលានរៀល) ។

-ក្រឡាបញ្ជីអានលិខិតលេខ ០២៤ ០៦/១០ អ.ជ.ព.ដ ចុះថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០១០ របស់គណៈកម្មាធិការចម្រុះកិច្ចការព្រំដែនដែលមានខ្លឹមសារដូចតទៅ :

**១-ក្លែងបន្លំឯកសារ :**

ការអះអាងថា ផែនទីខ្នាត ១/១០០ ០០០ ដែលមានក្រឡាការ៉ូ (គឺជាខ្សែបណ្តាញចតុរង្គ-Grid) នៅក្នុងគេហទំព័រលោក សម រង្ស៊ី ថាជាច្បាប់ចម្លងនៃផែនទីផ្លូវការ ដែលរាជរដ្ឋាភិបាលកម្ពុជាបានតម្កល់ទុកនៅអង្គការសហប្រជាជាតិនាខែមីនា ឆ្នាំ១៩៦៤ នោះ មិនត្រឹមត្រូវទេ ដោយផែនទីដែលបានយកទៅតម្កល់នោះគ្មានក្រឡាការ៉ូទេ។ ការអះអាងរបស់លោក សម រង្ស៊ី ដែលថា នៅលើផែនទីទាំងអស់សុទ្ធតែមានក្រឡាការ៉ូដែលគេហៅថា graticule នោះបញ្ជាក់ជាថ្មីថា លោក សម រង្ស៊ី ពុំយល់ដឹងអ្វីទាល់តែសោះពីបញ្ហាផែនទី។ សូមបញ្ជាក់ថា graticule គឺបណ្តាញខ្សែរយៈទទឹង (Parallèle) និងខ្សែរយៈបណ្តោយ (méridien) ខ្នាតរង្វាស់ដែលប្រើក្នុងបណ្តាញនេះ គឺមានតម្លៃគិតជាមុម តែពុំមែន grid របស់ផែនទី UTM ដែលបណ្តាញខ្សែក្រឡាការ៉ូសម្រាប់ការវាស់វែងកំណត់និយាមការចំណុច ការគណនាចម្ងាយរវាងចំណុចនីមួយៗ និងការគណនាក្រឡាផ្ទៃ ក្នុងខ្នាតរង្វាស់ដែលមានតម្លៃគិតជាម៉ែត្រនោះទេ។ ដូច្នេះ ការដែលយក graticule មកប្រៀបធៀបជាមួយ grid គឺជាការខុស។ ផែនទីក្រុមភូមិសាស្ត្រឥណ្ឌូចិន (SGI) ខ្នាត ១/១០០ ០០០ ពីដើមឡើយ ពុំមានបង្ហាញខ្សែបណ្តាញក្រឡាការ៉ូ (grid UTM) ទេ មានតែខ្សែ graticule ដែលមានតម្លៃជា Grade (100 Grade=$90^0$) ។ សរុបសេចក្តីមក ការដែលលោក សម រង្ស៊ី បានយកផែនទីខ្នាត ១/១០០ ០០០ ធ្វើការប្រើប្រាស់ និងផ្សព្វផ្សាយនោះ មានក្រឡាការ៉ូ។ តាមពិតផែនទីដែលរាជរដ្ឋាភិបាលកម្ពុជា បានតម្កល់ទុកនៅអង្គការសហប្រជាជាតិ នាខែមីនា ឆ្នាំ១៩៦៤ ពុំមានក្រឡាការ៉ូទេ មានន័យថា លោក សម រង្ស៊ី បានក្លែងបន្លំផែនទីដែលរាជរដ្ឋាភិបាលបានតម្កល់ទុកនៅអង្គការសហប្រជាជាតិ ។

**២-ផលិតផែនទីក្លែងក្លាយ និងផ្សព្វផ្សាយព័ត៌មានមិនពិត :**

លោក សម រង្ស៊ី បានផ្សព្វផ្សាយផែនទីមួយដែលលោកធ្វើដោយខ្លួនលោក ដែលនៅក្នុងបណ្តាសន្លឹកផែនទីនោះ លោក សម រង្ស៊ី ធ្វើការបញ្ជាក់ទីតាំងបង្គោលព្រំដែនលេខ ១៨៤ ១៨៥ ១៨៦ និង ១៨៧ ពុំត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសពិតប្រាកដ ធ្វើឱ្យបណ្តាទីតាំងបង្គោលព្រំដែនមាននៅក្នុងផែនទីនោះ បង្ហាញខុសទីតាំងពិតប្រាកដរបស់បង្គោល។ មូលហេតុនៃការខុសគ្នា គឺដោយសារលោក សម រង្ស៊ី បានយកទិន្នន័យទីតាំងបង្គោលព្រំដែន វាស់វែងដោយប្រើឧបករណ៍ GPS ដែលមានទិន្នន័យយោង WGS-84 មកដាក់លើផែនទីដែលមានទិន្នន័យយោងឥណ្ឌា ១៩៦០ (Datum Indian 1960) តែម្តង ដោយពុំបានធ្វើការបំលែងទិន្នន័យពីទិន្នន័យយោង WGS-84 មកទិន្នន័យយោងឥណ្ឌា ១៩៦០ (Datum Indian 1960) ដូចផែនទីឡើយ។ លោក សម រង្ស៊ី បានយល់ច្បាស់ហើយថា លោកមិនអាចយកទិន្នន័យបង្គោលព្រំដែនទាំងបួន ដែលលោកយកបាន បន្ទាប់ពីលោកចុះលើដីដាក់ស្តែងនៅទីតាំងបណ្តោះអាសន្នរបស់បង្គោលទាំងនោះ មកដាក់ក្នុងផែនទីរបស់ DMA ឬ SGI ដែលមានទិន្នន័យយោងខុសគ្នាជាមួយ GPS ដែលលោកយកទៅវាស់វែងនោះទេ តែដោយលោក សម រង្ស៊ី មានចេតនាបន្លំទិន្នន័យ ដើម្បីចោទប្រកាន់រាជរដ្ឋាភិបាល ទើបលោកធ្វើដូច្នេះ។

ទិន្នន័យយោង (Map Datum) : នេះជាលក្ខណៈពិសេសរបស់ផែនទី ដែលបញ្ជាក់ពីភាពច្បាស់លាស់របស់ផែនទីនោះ។ ទិន្នន័យយោងបង្ហាញពីការគណនាបែបគណិតវិទ្យា សម្រាប់ធ្វើការបង្ហាញ និងបកស្រាយនូវភាពសុក្រឹតរបស់រូបរាងនៃផ្ទៃលើសំបកផែនដី ទៅលើសន្លឹកក្រដាសផែនទីឱ្យបានច្បាស់លាស់។ ដូចជាបណ្តាផែនទីដែលបានផលិត និងប្រើប្រាស់ជាទូទៅនៅក្នុងស្រុកខ្មែរ មានការបញ្ជាក់ច្បាស់លាស់ពីទិន្នន័យយោង (datum) ដើម្បីឱ្យអ្នកប្រើប្រាស់មានលទ្ធភាពប្រើប្រាស់ផែនទីនេះបានច្បាស់លាស់ និងមិនមានកំហុស។

ឧទាហរណ៍ : -ផែនទី DMA ដែលផលិតក្នុងអំឡុងឆ្នាំ ១៩៦០-៧០ ដោយកងទ័ពសហរដ្ឋអាមេរិក មានមាត្រដ្ឋាន ១/៥០.០០០ បានបញ្ជាក់ច្បាស់លាស់ គឺចំណោលអ៊ុយតេអឹម (Projection UTM) និងមានទិន្នន័យយោងឥណ្ឌា ១៩៦០ (datum Indian 1960)។

-ផែនទីរូបភាពពីផ្កាយរណបដូចជា google map បានប្រើប្រាស់ទិន្នន័យយោង WGS84។

- ផែនទី SGI ដែលផលិតក្នុងអំឡុងឆ្នាំ ១៩៥០-៦០ ដោយក្រុមភូមិសាស្ត្រឥណ្ឌូចិន មានមាត្រដ្ឋាន ១/១០០.០០០ បានបញ្ជាក់តែចំណោលបោន (Projection Bonne) តែមិនមានសរសេរបញ្ជាក់ថា ជាទិន្នន័យយោងអ្វីឡើយ។

ជារួម រាល់ទិន្នន័យ និយាមការដែលទទួលបានពីឧបករណ៍ GPS ភាគច្រើនមានទិន្នន័យយោងជា WGS84។ ហេតុនេះ បើចង់ប្រើប្រាស់ទិន្នន័យនេះឱ្យបានត្រឹមត្រូវ ដើម្បីបញ្ចូលក្នុងផែនទី DMA ដែលមានចំណោលអ៊ុយតេអ៊ឹម (Projection UTM) និងមានទិន្នន័យយោងឥណ្ឌា ១៩៦០ (datum Indian 1960) ត្រូវធ្វើការបំលែង។ បើមិនមានធ្វើការបំលែងទេ នោះចំណុចដែលទទួល

បានពីការយកនិយាមការ WGS-84 មកប្រើក្នុងផែនទីដែលមាន Datum Indian 1960 មានភាពខុសគ្នាប្រហែល ៥៣០ ម ។

**ឧទាហរណ៍ :** ចំពោះទីតាំងបង្គោលព្រំដែនលេខ ១៨៤ ១៨៥ ១៨៦ និង ១៨៧ ដែលលោក សម រង្ស៊ី បានធ្វើការផ្សព្វផ្សាយតាមគេហទំព័ររបស់លោក មាននិយាមការភូមិសាស្ត្រ វាស់វែងដោយឧបករណ៍ GPS មាន Datum WGS-84 យើងអាចធ្វើការបំលែងបានជាតារាងដូចតទៅ :

តារាងចំណុច GPS នៃបង្គោលព្រំដែនរបស់លោក សម រង្ស៊ី និងការធ្វើបំលែងទិន្នន័យយោង :

| | គេហទំព័ររបស់លោក សម រង្ស៊ី | | គេហទំព័ររបស់លោក សម រង្ស៊ី | | ការធ្វើបំលែង Dutum | |
|---|---|---|---|---|---|---|
| លេខ បង្គោល | និយាម.ភូមិ WGS84 (Longitude) | និយាម.ភូមិ WGS84 (Latitude) | និយាម.ការ៉ូ X-WGS84 (m) | និយាម.ការ៉ូ Y-WGS84 (m) | និយាម.ការ៉ូ X-Ind.60 (m) | និយាម.ការ៉ូ Y-Ind.60 (m) |
| 184 | 106$^0$8'46.02" | 10$^0$57'29.46" | 625 231 | 1 211 593 | 625 644 | 1 211 250 |
| 185 | 106$^0$9'6.12" | 10$^0$56'31.68" | 625 848 | 1 209 821 | 626 261 | 1 209 478 |
| 186 | 106$^0$8'42.24" | 10$^0$55'46.80" | 625 128 | 1 208 439 | 625 541 | 1 208 096 |
| 187 | 106$^0$8'16.32" | 10$^0$54'57.78" | 624 347 | 1 206 930 | 624 760 | 1 206 588 |

បណ្ដាចំណុចដែលមានបញ្ជាក់ក្នុងតារាងនេះ អ្នកឯកទេសយើងបានធ្វើការកំណត់ទីតាំងបង្គោលព្រំដែនត្រឹមត្រូវដូចមានបញ្ជាក់ក្នុងផែនទីភ្ជាប់ជាមួយស្រាប់ ដោយធ្វើការបំលែងនិយាមការឱ្យដូចទិន្នន័យយោងផែនទី ។

**សេចក្ដីសន្និដ្ឋាន :**

តាមបច្ចេកទេស ផែនទីមានទិន្នន័យយោងឥណ្ឌា ១៩៦០ (datum Indian 1960) ចំណុចទីតាំងដែលត្រូវកំណត់ត្រូវមានទិន្នន័យយោងឥណ្ឌា ១៩៦០ (datum Indian 1960) ដូចគ្នា។ តែបើផែនទីមានទិន្នន័យយោង WGS-84 (Datum WGS-84) ចំណុចទីតាំងដែលត្រូវកំណត់ ត្រូវមានទិន្នន័យយោងដូចគ្នាគឺ WGS-84 (Datum WGS-84) ។

ហេតុនេះ ផែនទីដែលលោក សម រង្ស៊ី បានផលិត និងបានធ្វើការផ្សព្វផ្សាយជាផែនទីមួយមិនត្រឹមត្រូវ ជាផែនទីក្លែងក្លាយ ព្រោះលោក សម រង្ស៊ី ធ្វើការកំណត់ទីតាំងបង្គោលមិនបានត្រឹមត្រូវតាមនីតិវិធី និងបន្លំទិន្នន័យយោង ជាពិសេសទៅទៀត ទីតាំងចំណុចបង្គោលលេខ ១៨៦ ជាចំណុចទីតាំងដែលលោកធ្វើការសន្មតដោយខ្លួនលោក ព្រោះក្រុមបច្ចេកទេសចម្រុះរបស់គណៈកម្មការព្រំដែនកម្ពុជា-វៀតណាម ពុំទាន់បានធ្វើការសិក្សាចំណុចនេះនៅឡើយ ។

-ក្រឡាបញ្ជីអានពាក្យស្នើសុំ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១០ របស់លោកមេធាវី **ជុង ជូងី** ។

-សាក្សីឈ្មោះ **អ៊ិត សុគ្គា** បានឆ្លើយថា : តាមការពិនិត្យទៅលើផែនទីដែលលោក សម រង្ស៊ី បានប្រើប្រាស់ និងផ្សព្វផ្សាយមានកំហុស ៤ចំណុចគឺ ទី១ ផែនទីដែលលោក សម រង្ស៊ី ប្រើប្រាស់មានក្រឡាការ៉ូ ឯផែនទីរបស់កម្ពុជាដែលតម្កល់ទុកនៅអង្គការសហប្រជាជាតិឆ្នាំ១៩៦៤ និង

ផែនទីឧបសម្ព័ន្ធអមសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ ពុំមានក្រឡាការ៉ូនៅលើសន្លឹកផែនទីទេ ។ ទី២ លោក សម រង្ស៊ី បានផលិតផែនទីមួយដោយមានកំណត់ទីតាំងបង្គោលព្រំដែនខុសពីទីតាំងបង្គោលព្រំដែន ដែលក្រុមបច្ចេកទេសចម្រុះកិច្ចការព្រំដែនបានកំណត់នៅក្នុងផែនទី ។ ទី៣ ប្រើប្រាស់និយាមការទីតាំងបង្គោលព្រំដែន ដោយប្រើប្រាស់បច្ចេកទេសមិនត្រឹមត្រូវ គឺយកនិយាមការទីតាំងបង្គោលព្រំដែនវាស់វែងដោយឧបករណ៍ GPS ដោយប្រើទិន្នន័យយោង (Datum) WGS 84 មកដាក់លើផែនទីដែលមានទិន្នន័យយោង Indian 1960 (Datum Indian 1960) ជាការពុំត្រឹមត្រូវ ។ ទី៤ ប្រើប្រាស់និយាមការកំណត់ទីតាំងបង្គោលព្រំដែនលេខ ១៨៦ ក្នុងពេលដែលក្រុមបច្ចេកទេសចម្រុះកិច្ចការព្រំដែននៃប្រទេសទាំងពីរកម្ពុជា-វៀតណាម ពុំទាន់បានកំណត់នៅលើដីនៅឡើយ ។ រហូតដល់ពេលនេះ ខ្លួនពុំទាន់បានផ្តល់សេចក្តីចម្លងនៃផែនទីដែលបានតម្កល់ទុកនៅអង្គការសហប្រជាជាតិជូនដល់តុលាការទេ ព្រោះខ្លួនពុំមានតួនាទីអ្វីត្រូវផ្តល់ឡើយ ។ ការប្រើនិយាមការខុសរបស់លោក សម រង្ស៊ី ធ្វើឱ្យការកំណត់បង្គោលព្រំដែនខុសទីតាំង ។ ការធ្វើបែបនោះដោយពុំបានបំលែងឱ្យបានត្រឹមត្រូវជាមុនទេ វាជាការខុសឆ្គងហើយ ។

-សាក្សីឈ្មោះ **ស៊ិន សុធានី** បានឆ្លើយថា : បញ្ហាដែលលោក សម រង្ស៊ី ប្រើប្រាស់ផែនទីមាន ៤ចំណុច : ទី១ ផែនទី SGI ខ្នាត ១/១០០ ០០០ ដែលតម្កល់នៅអង្គការសហប្រជាជាតិឆ្នាំ ១៩៦៤ និងផែនទីឧបសម្ព័ន្ធអមសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ ពុំមានក្រឡាការ៉ូទេ តែផែនទីដែលលោក សម រង្ស៊ី ប្រើ និងផ្សព្វផ្សាយនោះមានក្រឡាការ៉ូ ។ ទី២ គំរុយបង្គោលព្រំដែនដែលលោក សម រង្ស៊ី កំណត់ខុសពីការកំណត់របស់ក្រុមបច្ចេកទេសចម្រុះកិច្ចការព្រំដែនបានកំណត់នៅក្នុងផែនទី ។ ទី៣ លោក សម រង្ស៊ី យកនិយាមការទីតាំងបង្គោលព្រំដែនវាស់វែងដោយឧបករណ៍ GPS ដោយប្រើទិន្នន័យយោង (Datum) WGS84 មកដាក់លើផែនទីដែលមានទិន្នន័យយោង Indian 1960 (Datum Indian 1960) ធ្វើឱ្យការកំណត់ទីតាំងខុស ។ គាត់ពុំធ្វើតាមទិន្នន័យយោងដែលមានបញ្ជាក់ក្នុងផែនទី ទើបទីតាំងខុសគ្នាទាំងស្រុង ។ លោក សម រង្ស៊ី បានកំណត់ទីតាំងបង្គោលព្រំដែនលេខ ១៨៦ ក្នុងពេលដែលក្រុមបច្ចេកទេសចម្រុះកិច្ចការព្រំដែននៃប្រទេសទាំងពីរកម្ពុជា-វៀតណាម ពុំទាន់បានកំណត់នៅលើដីនៅឡើយ ។ ផែនទីមាន២គឺ ទី១ ជា UTM គិតជាម៉ែត្រអាច ១ ប្រឡោះ ប្រវែង ១គីឡូម៉ែត្រ ទី២ គិតជាក្រាត ឬគិតជាមុម ផែនទីទាំងពីរនេះមានលក្ខណៈខុសគ្នា ។ នីតិវិធីកំណត់បង្គោលព្រំដែនរបស់ប្រទេសនីមួយៗ ត្រូវធ្វើការពិភាក្សាយ៉ាងហ្មត់ចត់ទើបឈានដល់ការកំណត់លើផែនទីបាន ហើយគេត្រូវការប្រើឧបករណ៍ទំនើបៗ ទើបអាចកំណត់ទីតាំងមួយៗបាន ។ ក្រោយមក ទើបបានជាចំណុចដែលហៅថា គំរុយនោះ ហើយយកគំរុយនោះមកសិក្សាបន្តទៀត ។ ទី៤ បង្គោលព្រំដែនលេខ ១៨៦ គណៈកម្មាធិការពុំទាន់បានកំណត់នៅឡើយទេ ស្រាប់តែលោក សម រង្ស៊ី បានកំណត់បង្គោលលេខ ១៨៦ នេះ ។ នីតិវិធីកំណត់បង្គោលព្រំដែន ជាលក្ខណៈបច្ចេកទេសមុនដំបូងពិភាក្សាគ្នាសិន រួចទើបទៅកំណត់នៅលើដីជាក់ស្តែង ជាពិសេស ចំពោះការកំណត់បង្គោល

ព្រំដែនរវាងកម្ពុជា-វៀតណាមបានប្រើដោយឧបករណ៍ និងបច្ចេកទេសទំនើប ទើបកំណត់បាននូវចំណុចមួយហៅថា គំរុយ ហើយទើបយកមកពិភាក្សាគ្នាទៀត ។ ចំពោះបង្គោលព្រំដែនលេខ ១៨៦ គណៈកម្មការបច្ចេកទេសព្រំដែនពុំទាន់បានធ្វើអ្វីទាំងអស់ តែលោក សម រង្ស៊ី បែរជាបានកំណត់បង្គោលលេខ ១៨៦ ទៅវិញ ។ លោក សម រង្ស៊ី បានផលិតផែនទីថ្មី ធ្វើសន្លឹកផែនទីថ្មី និងយកទិន្នន័យ WGS84 មកប្រើលើផែនទីមាននិយាមការចាស់ដោយពុំបានបំលែងទេ ទើបវាខុសពីទីតាំងពិតដល់ទៅជិត ៥៣០ម៉ែត្រ ។ លោក សម រង្ស៊ី បានផលិតផែនទីថ្មី ព្រោះកាលណាព្រីន ឬបោះពុម្ពថ្មី គឺថ្មីហើយ ។ ផែនទីដែលលោក សម រង្ស៊ី យកមកប្រើជាផែនទីកាត់មួយប្រឡោះ ពុំមែនជាផែនទីកម្ពុជាទាំងមូលទេ ។ ក្នុងនាមខ្លួនជាអ្នកបច្ចេកទេសផែនទី ផែនទីដែលលោក សម រង្ស៊ី ផ្សព្វផ្សាយតាមអ៊ិនធឺណេតជាផែនទីមិនផ្លូវការទេ ។ ផែនទីទាំងពីរដែលលោក សម រង្ស៊ី ប្រើប្រាស់នោះពុំមែនជាផែនទីផ្លូវការទេ ។ បង្គោលព្រំដែនលេខ ១៨៥ លោក សម រង្ស៊ី បានដកចេញហើយ ។

-សាក្សីឈ្មោះ **ស៊ិន សុធានី** និងឈ្មោះ **អ៊ិត សុត្ថា** បានបញ្ជាំងស្លាយរូបភាពផែនទីសន្លឹកទី១ ជាផែនទីដែលពុំមានក្រឡាការ៉ូ ។ ស្លាយផែនទីសន្លឹកទី២ ដែលមានក្រឡាការ៉ូ ហើយបញ្ជាក់ថា ផែនទីសន្លឹកទី២ នេះឃើញមានចំណុចសំខាន់នៅខាងក្រោមថា ជាផែនទីតម្កល់ទុកនៅអង្គការសហប្រជាជាតិ ហើយចំណុចខ្មែង១ នេះជាទីតាំងបង្គោលព្រំដែនដែលលោក សម រង្ស៊ី បង្ហាញដោយទិន្នន័យ GPS ដែលខុសពីចំណុចដែលអ្នកបច្ចេកទេសព្រំដែនជាខ្សែបន្ទាត់ពណ៌ក្រហម មូលហេតុដែលចំណុចខ្មែងមិននៅលើខ្សែក្រហមដោយសារលោក សម រង្ស៊ី យកនិយាមការមកប្រើប្រាស់មិនត្រឹមត្រូវ។ ផែនទីនេះគឺជាផែនទីដែលលោក សម រង្ស៊ី បានកាត់មួយផ្នែក ពុំមែនជាផែនទីទាំងមូលទេ។ ផែនទីដែលបានតម្កល់ទុកនៅអង្គការសហប្រជាជាតិ មិនមែនជាផែនទី SGI ពុំមានខ្សែក្រឡាជា Grid ទេ មានតែខ្សែក្រឡា Graticule ដែលគិតជាមុមរយៈទទឹង និងរយៈបណ្តោយ ។ ផែនទីនេះគ្មាន Grid UTM ទេ ។ គណៈកម្មាធិការព្រំដែន ប្រើប្រាស់ផែនទីខ្នាត ១/១០០ ០០០ គ្មានក្រឡាការ៉ូទេ ។ ផែនទីខ្នាត ១/៥០ ០០០ មានក្រឡាការ៉ូ (Grid) គិតជាម៉ែត្រ និងមាន (Graticule) គិតជាមុមផងដែរ ។ នេះពុំមែនជាផែនទីមាន Datum WGS 84 ទេ វាជាផែនទីមាន Datum Indian 1960 ។ ការយកទិន្នន័យបានមកពីការប្រើឧបករណ៍ GPS មាន Datum WGS 84 ដាក់លើផែនទី Datum Indian 1960 ដោយមិនបានបំលែងទិន្នន័យឱ្យបានត្រឹមត្រូវគឺមានភាពខុសគ្នា ៥៣០ម៉ែត្រ។ គេអាចដឹងថា ផែនទីណាមួយជាផែនទី Datum Indian 1960 ឬផែនទី Datum WGS 84 បានដោយពិនិត្យទៅលើប្រវត្តិនៃការកសាងវា និងចំណុចនៅលើសន្លឹកផែនទី ។ Datum គឺជាការគណនាផ្ទៃនៃសំបកផែនដីមកដាក់លើផ្ទៃរាប ព្រោះផែនដីមានរាងមូល ។ ផែនទីដែលគិតជាមុម គឺមានន័យថា គិតពីអក្សរផែនទី ដែលដើម្បីងាយស្រួល ទើបអ្នកបច្ចេកទេសខិតខំបំលែងមកជាផែនទី ដែលគិតជាម៉ែត្រវិញ ។

**-លោក គី តិច មេធាវីរាជរដ្ឋាភិបាលធ្វើសេចក្តីសន្និដ្ឋានថា** : ហេតុដែលនាំឱ្យកើតមានបណ្តឹងពីរាជរដ្ឋាភិបាល គឺផ្តើមឡើងដោយអំពើរបស់លោក សម រង្ស៊ី បានធ្វើសំភាសន៍ជាសម្លេងផ្ទាល់ និងបង្ហាញនូវរូបភាពឯកសារ ក្លែងបន្លំ ដូចជារូបថត ផែនទី ខ្សែបន្ទាត់ព្រំដែនព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម ដើម្បីយកមកប្រើប្រាស់ បង្ហាញពន្យល់ ជាអក្សរជាលេខជាច្រើនទំព័រតាមប្រព័ន្ធអ៊ីនធឺណែត ក្នុងគោលបំណងធ្វើការបំភាន់ មតិជាតិ និងអន្តរជាតិឱ្យយល់ខុសពីការងាររបស់គណៈកម្មការចម្រុះកិច្ចការព្រំដែនកម្ពុជាវៀតណាម។ លោក សម រង្ស៊ី បានយកផែនទីទៅប្រើប្រាស់មិនត្រឹមត្រូវ ហើយយកចំណុចវិវាទមកដាក់ក្នុងផែនទីមិនត្រឹមត្រូវដែលក្នុងនោះរួមមាន :

-ផែនទី SGI ខ្នាត ១/១០០.០០០ ដែលបានតម្កល់នៅអង្គការសហប្រជាជាតិឆ្នាំ ១៩៦៥ និងផែនទីឧបសម្ព័ន្ធអមសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ ២០០៥ ពុំមានក្រឡាការ៉ូ នៅលើសន្លឹកផែនទីដូចផែនទីដែលលោក សម រង្ស៊ី បានបង្ហាញ និងផ្សព្វផ្សាយនោះទេ។

-លោក សម រង្ស៊ី បានផលិតផែនទីថ្មីមួយ ដោយមានកំណត់ទីតាំងបង្គោលព្រំដែនខុសពីទីតាំងបង្គោលព្រំដែន ដែលក្រុមបច្ចេកទេសចម្រុះកិច្ចការព្រំដែនបានកំណត់នៅក្នុងផែនទី។

-ប្រើប្រាស់និយាមការទីតាំងបង្គោលព្រំដែន ដោយប្រើប្រាស់បច្ចេកទេសមិនត្រឹមត្រូវ គឺយកនិយាមការទីតាំងបង្គោលព្រំដែនវាស់វែងដោយឧបករណ៍ GPS ដោយប្រើទិន្នន័យយោង Datum WGS 84 មកដាក់លើផែនទីដែលមានទិន្នន័យយោង Indian 1960 Datum Indian 1960 ការពិតការកំណត់ទីតាំងណាមួយនៅលើផែនទី ទាល់តែចំណុចទីតាំងនោះមាននិយាមការដែលមានទិន្នន័យយោង Datum ដូចគ្នា។

ក្នុងនោះមានភស្តុតាងបញ្ជាក់ច្បាស់ដែលយើងខ្ញុំបានដាក់ជូនតុលាការរួចហើយ ដូចជាភស្តុតាងជាឯកសារ ភស្តុតាងជាសាក្សី និងភស្តុតាងជាសម្លេង។

ក្រោយពីបានស្តាប់ការបំភ្លឺ ការពន្យល់ដោយសាក្សីជំនាញបច្ចេកទេស និងភស្តុតាងទាំងអស់ដែលមានក្នុងសំណុំរឿង ហើយផ្ទៀងផ្ទាត់ជាមួយនឹងអំពើដែលលោក សម រង្ស៊ី បានប្រព្រឹត្តបញ្ជាក់យ៉ាងច្បាស់ថា លោក សម រង្ស៊ី ពិតជាមានចេតនាទុច្ចរិតប្រើប្រាស់បច្ចេកវិទ្យា ធ្វើឱ្យចំណុចទាំងឡាយដូចជា : ខ្សែបន្ទាត់ព្រំដែន ចំណុចតម្រុយបង្គោលព្រំដែនរំកិលខុសពីទីតាំងពិតប្រាកដ ហើយលោក សម រង្ស៊ី បានប្រើប្រាស់ឯកសារនោះ ដើម្បីបំភាន់ព័ត៌មាន ទំលាក់កំហុសដោយអសុទ្ធចិត្តមកលើរាជរដ្ឋាភិបាលកម្ពុជា ក្នុងបំណងបំផ្លិចបំផ្លាញ ធ្វើឱ្យកើតកោលាហលដល់សន្តិសុខសាធារណៈ។ លើសពីនេះទៅទៀត លោក សម រង្ស៊ី ក៏បានប្រើប្រាស់គ្រប់មធ្យោបាយ ដើម្បីផ្សាយនូវព័ត៌មានប្រឌិត ព័ត៌មានក្លែងក្លាយនេះ បំភាន់មតិជាតិ និងអន្តរជាតិពាសពេញពិភពលោក។ លោក សម រង្ស៊ី មានចេតនាធ្វើឱ្យមតិជាតិ និងអន្តរជាតិ ជាពិសេសប្រជាពលរដ្ឋកម្ពុជាដែលពុំមានការយល់ដឹងច្បាស់លាស់អំពីបញ្ហាផែនទីនេះ មានការយល់ច្រឡំដល់រាជរដ្ឋាភិបាលកម្ពុជា ពិសេសប្រមុខដឹកនាំ

នាំជាន់ខ្ពស់កម្ពុជាថា បានកាត់ដីរបស់ខ្លួនឱ្យទៅប្រទេសវៀតណាម ។ បញ្ហានេះនាំឱ្យខូចខាតយ៉ាងធ្ងន់ធ្ងរដល់កិច្ចសហប្រតិបត្តិការកម្ពុជា-វៀតណាម ជាពិសេសក្នុងកិច្ចការកំណត់ព្រំដែនរវាងប្រទេសទាំងពីរ ។ អំពើនេះក៏បានបណ្តាលឱ្យមានការរាំងស្ទះការងាររបស់គណៈកម្មការចម្រុះកិច្ចការព្រំដែន និងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កិត្យានុភាពនៃប្រទេសកម្ពុជាទាំងមូល ។

ទាំងនេះគឺពិតជា អំពើក្លែងឯកសារសាធារណៈ និងផ្សព្វផ្សាយព័ត៌មានមិនពិត ដែលបំពានទៅនឹងមាត្រា ៤៩ និងមាត្រា ៦២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

ហេតុដូច្នេះ បន្ថែមពីលើការស្នើសុំឱ្យមានការផ្តន្ទាទោសលោក សម រង្ស៊ី តាមច្បាប់ក្នុងនាមមេធាវីតំណាងរាជរដ្ឋាភិបាលកម្ពុជា សំណូមពរឱ្យតុលាការសម្រេចឱ្យលោក សម រង្ស៊ី សងការខូចខាតដោយសារអំពើល្មើសច្បាប់របស់គាត់ ជូនមករាជរដ្ឋាភិបាលកម្ពុជាចំនួន ១០០ លានរៀល ។

ចំពោះការលើកឡើងរបស់មេធាវីលោក សម រង្ស៊ី ថាលោកសាស្ត្រាចារ្យ Caloz គឺជាអ្នកជំនាញគិតគូរខាងផែនទី ហើយឱ្យយកលទ្ធផលនេះមកពិចារណា ខ្លួនសូមតុលាការមេត្តាទាត់ចោលដោយហេតុថា បុគ្គល Caloz នេះជាបុគ្គលដែលយើងទាំងអស់គ្នាពុំដែលស្គាល់ ជាបុគ្គលដែលពុំមានច្បាប់ណាទទួលស្គាល់គាត់នោះទេ គាត់ជាបុគ្គលដែលគាំទ្រលោក សម រង្ស៊ី បើប្រៀបធៀបជាមួយនឹងគណៈកម្មាធិការព្រំដែន គឺគណៈកម្មការនេះមានការទទួលស្គាល់ដោយរដ្ឋសភាកម្ពុជាផង និងព្រះមហាក្សត្រផង ហើយគណៈកម្មការនេះ ត្រូវបានទទួលសិទ្ធិផ្តាច់មុខក្នុងការបំពេញភារកិច្ចលើកិច្ចការព្រំដែនរវាងកម្ពុជា-វៀតណាម ។

ការលើកឡើង សួរពាក់ព័ន្ធនឹងការដកបង្គោលព្រំដែន ឬអំពើបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ និងញុះញង់ជាតិសាសន៍ គឺជាសំណួរដែលធ្វើឡើងប្រាស់ចាកកម្មវត្ថុ និងផុយពីបទចោទនៅក្នុងរឿងដែលត្រូវធ្វើសវនាការពេលនេះ រឿងក្តីទាំងនោះត្រូវបានសាលាដំបូងខេត្តស្វាយរៀងជំនុំជម្រះរួចហើយ ។ ការស្នើសុំឱ្យបង្កើតគណៈកម្មការចុះវាស់វែងទីតាំងតម្រុយបង្គោលជាក់ស្តែងក៏ត្រូវបានចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញបដិសេធចោល ដោយមូលហេតុសំណើនេះស្នើឡើងផុយពីបទចោទរបស់តំណាងអយ្យការសាលាដំបូងរាជធានីភ្នំពេញនោះដែរ ។

ចំពោះការលើកឡើងការពារដោយមេធាវីលោក សម រង្ស៊ី ថាលោក សម រង្ស៊ី ជាតំណាងរាស្ត្រមានសិទ្ធិពេញលេញក្នុងការចុះទៅធ្វើការងារព្រំដែននោះ ខ្លួនសូមបញ្ជាក់ថា នៅកម្ពុជាមានច្បាប់ មានការបែងចែកអំណាចដាច់ដោយឡែកពីគ្នារវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។ លោក សម រង្ស៊ី មិនត្រូវទៅជ្រៀតជ្រែកក្នុងអំណាចនីតិប្រតិបត្តិបានទេ ព្រោះគាត់មានតួនាទីស្ថិតក្នុងអំណាចនីតិបញ្ញត្តិ បើគាត់មិនឯកភាព ឬមើលឃើញកំហុសឆ្គងក្នុងការអនុវត្តដោយអំណាចនីតិប្រតិបត្តិ គាត់អាចតវ៉ាតាមផ្លូវច្បាប់ ។

**-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា** : ឆ្លងតាមការសួរដេញដោលនាំពេលសវនាការ និងតាមការពិនិត្យឯកសារក្នុងសំណុំរឿងនេះមក ក្នុងនាមជាតំណាងអយ្យការសុំធ្វើការ

សន្និដ្ឋានពីធាតុផ្សំនៃបទល្មើសនេះជា ៤ចំណុច ។ ទី១ លោក សម រង្ស៊ី ជាប្រធាននៃបទល្មើសជានីតិជន ជាបញ្ហាវិន្ទមកពីប្រទេសបារាំង ជាតំណាងរាស្ត្រ និងជាអ្នកនយោបាយជាន់ខ្ពស់ផង ។ ទី២ មានឆន្ទៈទុច្ចរិតក្នុងបំណងបំភាន់មតិជាតិ និងអន្តរជាតិឱ្យយល់ខុសពីការពិតលើបញ្ហាជំនាញបច្ចេកទេសរបស់គណៈកម្មាធិការចម្រុះទទួលបន្ទុកកិច្ចការព្រំដែនកម្ពុជា-វៀតណាម ដើម្បីទំលាក់កំហុសទៅលើប្រមុខដឹកនាំរាជរដ្ឋាភិបាលកម្ពុជា។ ទី៣ ធាតុសត្យានុម័តគឺលោក សម រង្ស៊ី យកផែនទីមកប្រើគឺផែនទីខ្នាត ១/១០០ 000 (ដែលមានក្រឡាការ៉េ) បោះពុម្ពដោយក្រុមភូមិសាស្ត្រឥណ្ឌូចិនផ្ទាំងលេខ 220V ឈ្មោះ Trang Band Quest ឆ្នាំ១៩៥២ ដោយ សម រង្ស៊ី អះអាងថាជាផែនទីផ្លូវការតម្កល់ទុកនៅអង្គការសហប្រជាជាតិ កាលពីខែមីនា ឆ្នាំ១៩៦៤ តាមពិតផែនទីដែលតម្កល់នៅអង្គការសហប្រជាជាតិ គឺពុំមានក្រឡាការ៉េទេ គឺមានតែរយៈទទឹង និងរយៈបណ្តោយ ។ បន្ទាប់មកមានផែនទីបោះពុម្ពដោយកងយោធាអាមេរិកខ្នាត ១/៥០ 000 UTM ផ្ទាំងលេខ 6230 IV ឈ្មោះ DUC HUE ឆ្នាំ ១៩៦៦ ប្រើទិន្នន័យយោង DATUM ឈ្មោះ Indian Datum ឆ្នាំ១៩៦០ ដែលផែនទីនេះមានក្រឡាការ៉េ ដោយការបោះពុម្ពនេះបានប្រើ Datum Indian 1960 បំលែងទៅ Datum WGS 84 ធ្វើទៅតាមលក្ខណៈបច្ចេកទេសផែនទីត្រឹមត្រូវហើយ គឺមានក្រឡាការ៉េនៅពីលើខ្សែរយៈទទឹង និងខ្សែរយៈបណ្តោយលើកមុន បានន័យថា ផែនទីតម្កល់នៅអង្គការសហប្រជាជាតិមុនគណនាជាមុម ឯផែនទីដែលអាមេរិកជួយធ្វើបោះពុម្ពក្រោយគណនាជាម៉ែត្រ ។ ការគណនាផែនទីតម្កល់នៅអង្គការសហប្រជាជាតិប្រើ Datum Indian 1960 ឯផែនទីបោះពុម្ពក្រោយប្រើ WGS84 ដែលគេប្រើជាសកល ។ តាមទិន្នន័យទីតាំងបង្គោលរបស់លោក សម រង្ស៊ី ដែលប្រើ GPS គឺជាទិន្នន័យប្រើប្រព័ន្ធនិយាមការស្ថិតក្នុងទិន្នន័យយោង Datum WGS84 ដែលខុសគ្នានឹងទិន្នន័យយោងរបស់ផែនទី UTM របស់ DMA អាមេរិក ដែលប្រើ Indian 1960 ។ មុននឹងយកទិន្នន័យទីតាំងបង្គោលព្រំដែនដែលបានមកពីការចុះទៅយកលើដីជាក់ស្តែងលោក សម រង្ស៊ី ត្រូវធ្វើការបំលែងពីទិន្នន័យយោង WGS84 មកទិន្នន័យយោង Indian Datum 1960 ដើម្បីយកវាមកដាក់លើផែនទីខ្នាត ១/៥០ 000 របស់ DMA ឬផែនទីខ្នាត១/ ១០០ 000 របស់ SGI ។ ការធ្វើផែនទីដែលលោក សម រង្ស៊ី ប្រើប្រាស់ និងផ្សព្វផ្សាយផែនទីនោះតាមអ៊ិនធឺណែតពុំត្រឹមត្រូវទេ ព្រោះជាក់ស្តែងឃើញថា ឃ្លាតគ្នាគឺខុសហើយ ។ លោក សម រង្ស៊ី អាចដឹងមុន ឬធ្វើជាមិនដឹងពីការប្រើប្រាស់ឧបករណ៍ GPS ក្នុងការជ្រើសរើសប្រើ Datum តែលោក សម រង្ស៊ី នៅតែធ្វើកំហុសនេះ ដើម្បីបំភាន់ប្រជារាស្ត្រ ។ លោក សម រង្ស៊ី ពុំយល់ ឬធ្វើពុំដឹង ពីភាពខុសគ្នា រវាងទិន្នន័យយោង Datum របស់ផែនទី DMA និង SGI ជាមួយទិន្នន័យយោងដែលប្រើក្នុងឧបករណ៍ GPS ។ លោក សម រង្ស៊ី មិនយល់ ឬធ្វើជាមិនយល់ពីបច្ចេកទេសធ្វើបំលែងដែលចាំបាច់ត្រូវធ្វើមុនយកមកចុចលើផែនទីដែលប្រើទិន្នន័យយោង Datum ខុសគ្នា ។ លោក សម រង្ស៊ី បានធ្វើការក្លែងបន្លំទិន្នន័យទីតាំងបង្គោលព្រំដែនដោយចេតនា ព្រោះរាល់អ្នកបច្ចេកទេសត្រូវតែដឹងថា ត្រូវតែធ្វើការបំលែងមុននឹងចុចទៅលើផែនទីបាន ។ ការផ្សព្វផ្សាយព័ត៌មានមិនពិតនឹង

លោក សម រង្ស៊ី បានផ្សព្វផ្សាយរូបភាព ឯកសារ អក្សរ ពន្យល់តាមប្រព័ន្ធអ៊ិនធឺណែតជាលក្ខណៈជំនាញបច្ចេកទេស ដោយអ្នកជំនាញភូមិសាស្ត្រអន្តរជាតិឈ្មោះ Régis Caloz និងដើម្បីឱ្យមតិជាតិ និងអន្តរជាតិយល់ ខុសពីការពិតលើកិច្ចការព្រំដែនរបស់គណៈកម្មាធិការព្រំដែនជាតិ ។ សរុបមកក្នុងនាមតំណាងអយ្យការ អាចសន្និដ្ឋានបានថា : ទីតាំងបង្គោលព្រំដែនដែលផ្ដល់ឱ្យដោយលោក សម រង្ស៊ី ដែលបានបញ្ជាក់ថា បានប្រើ GPS និងមានដាក់បង្ហាញនៅលើរូបភាពរបស់ Google Earth នោះគឺទិន្នន័យទាំងនោះស្ថិតនៅក្នុងប្រព័ន្ធនិយាមការ Datum WGS84 ដែលខុសគ្នានឹងទិន្នន័យយោងរបស់ផែនទី UTM របស់ DMA អាមេរិកដែលមានឈ្មោះថា Indian 1960 ដោយសារប្រភពទិន្នន័យផ្សេងគ្នា ទើបទីតាំងបង្គោលដែល សម រង្ស៊ី បានដាក់បង្ហាញលើផែនទី UTM ខ្នាត ១/៥០ 000 របស់ DMA ក៏ដូចជាដាក់បង្ហាញនៅលើផែនទី SGI ខ្នាត ១/១០០ 000 ដែលមានក្រឡាការ៉ូ នោះគឺខុសពុំត្រូវតាមទីតាំងពិតប្រាកដរបស់វាឡើយ ។ របៀបផ្ទេរព័ត៌មានទីតាំងបង្គោលដែល សម រង្ស៊ី បានបង្ហាញក្នុងឯកសារជារបៀបចាស់ហួសសម័យ ដែលមិនអាចយកមកប្រើជាមួយ GPS ដែលប្រើ Datum WGS84 នេះបានឡើយ ហេតុនេះ ទើបវាខុសគ្នា ដោយមានការលំអៀងច្រើនរហូតធ្វើឱ្យបង្គោលខុសពីទីតាំងដែលគណៈកម្មការព្រំដែនកម្ពុជា-វៀតណាមបានកំណត់ ។ លោក សម រង្ស៊ី នៅតែព្យាយាមពន្យល់ថា ការដាក់ទីតាំងចំណុចទាំង៤ លើផែនទីត្រឹមត្រូវដោយបង្ហាញពីការប្រើ Geographic Calculator ក្នុងឯកសារបន្ថែមរបស់គាត់ទៀត ប៉ុន្តែនេះក៏នៅតែពុំត្រឹមត្រូវដែរ ព្រោះគេអាចប្រើ Calculator នេះដោយរបៀបផ្សេងពីអ្វី ដែលគាត់បានប្រើ គឺត្រូវប្ដូរពី Datum WGS84 ទៅ Indian1960 ពុំមែនពីនិយាមការភូមិសាស្ត្រទៅនិយាមការ Grid ទេ ។ តាមបច្ចេកទេស មុននឹងយកទិន្នន័យទីតាំងបង្គោលដែលបានមកពីការចុះទៅ យកនៅលើដីជាក់ស្ដែង ដោយប្រើទិន្នន័យយោង Datum WGS84 ត្រូវបំលែងពីទិន្នន័យយោង Datum WGS84 មក Datum Indian 1960 ទើបយកវាមកដាក់លើផែនទីខ្នាត ១/៥០ 000 របស់ DMA ឬផែនទី Bonne ១/១០០ 000 របស់ក្រុមភូមិសាស្ត្រឥណ្ឌូចិនដែលមានបណ្ដាញក្រឡាការ៉ូ Datum1960 នេះជាការត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ។ លោក សម រង្ស៊ី បានព្យាយាមកំណត់ បង្គោលព្រំដែនពុំត្រឹមត្រូវ ។ តាមច្បាប់បណ្ណសាររបស់ព្រះរាជាណាចក្រកម្ពុជា ផែនទីដែលលោក សម រង្ស៊ី ប្រើប្រាស់នេះគឺជាឯកសារសាធារណៈហើយ ច្បាប់ចាត់ទុកថាជាឯកសារសាធារណៈទៅហើយ ប្រហែលជាលោកមេធាវីការពារជនជាប់ចោទពុំបានមើលច្បាប់បណ្ណសារកម្ពុជាទេ ទើបថាផែនទី លោក សម រង្ស៊ី ប្រើ ពុំមែនជាឯកសារសាធារណៈនោះ ។ យោងតាមមាត្រា ៤៩ និងមាត្រា ៦២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ឃើញថា មានធាតុផ្សំ និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ សម រង្ស៊ី ពីបទ ក្លែងបន្លំឯកសារសាធារណៈដោយប្រើប្រាស់លេខ អក្សរ បច្ចេកទេសជំនាញ ខ្សែបន្ទាត់ ព្រំដែនកម្ពុជា-វៀតណាម ព្រមទាំងផ្សព្វផ្សាយព័ត៌មានប្រឌិតក្លែងក្លាយជារូបភាព និងអក្សរ តាមប្រព័ន្ធអ៊ិនធឺណែតពីប្រទេសបារាំងទៅសកលលោក ក្នុងគោលបំណងបំភាន់មតិជាតិ និងអន្តរជាតិឱ្យយល់ខុសពីការពិត ដើម្បី

ទម្លាក់កំហុសដោយអសុទ្ធចិត្តលើប្រមុខរដ្ឋាភិបាលកម្ពុជា ។ ក្នុងពេលសវនាការសាក្សីជាអ្នកជំនាញខាងផែនទីបានព្យាយាមពន្យល់លើផែនទី ហើយអង្គសវនាការក៏បានជជែកពីភស្តុតាងដាក់បន្ទុក និងភស្តុតាងដាក់បន្ទុករួចហើយដែរ ។ ចំពោះការលើកឡើងរបស់មេធាវីការពារជនជាប់ចោទដែលបានលើកឡើងថា គួរតុលាការបង្កើតគណៈកម្មការព្រំដែនមួយនោះ តំណាងអយ្យការយល់ថា ពុំចាំបាច់ទេ ព្រោះមានគណៈកម្មធិការចំរុះកិច្ចការព្រំដែនស្រាប់ទៅហើយ ហេតុអ្វីបានចាំបាច់បង្កើតគណៈកម្មការក្នុងគណៈកម្មាធិការទៀត ? ហើយការលើកឡើងពីសាស្ត្រាចារ្យឈ្មោះ Caloz សុំបដិសេធចោល ហេតុអ្វីចាំបាច់ទៅជឿលើមនុស្សម្នាក់ឈ្មោះ Caloz ដែលយើងពុំដែលស្គាល់ផងនោះ យើងមានគណៈកម្មធិការចំរុះព្រំដែនដែលត្រូវបានបង្កើតឡើងយ៉ាងត្រឹមត្រូវហើយ ។ ផែនទីដែលជាឯកសារដើមត្រូវបានចុះហត្ថលេខាដោយឥស្សរជនជាន់ខ្ពស់ ហើយដាក់តំកល់ទុកនៅអង្គការសហប្រជាជាតិហើយ ពុំអាចយកមកបានទេ ។ តំណាងអយ្យការស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះ ផ្តន្ទាទោសជនជាប់ចោទខាងលើនេះតាមច្បាប់ឱ្យបានតឹងរឹង ។

**-លោក ជួង ជូងី មេធាវីការពារជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា :** តំណាងអយ្យការបានចោទប្រកាន់កូនក្តីខ្លួនពីបទ ក្លែងឯកសារសាធារណៈ និងការផ្សព្វផ្សាយព័ត៌មានមិនពិត តាមមាត្រា ៤៩ និងមាត្រា ៦២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ សូមជម្រាបថា ភស្តុតាងត្រូវតែដាក់មកជាសាធារណៈម្តងមួយៗ ក្នុងសវនាការ ពុំអាចលាក់ទៀតបានទេ បើពុំដូច្នេះទេវាជាវិមតិសង្ស័យ ហើយវិមតិសង្ស័យត្រូវបានជាប្រយោជន៍របស់កូនក្តីខ្លួនជានិច្ច ។ តាមខ្លឹមសារនៃមាត្រា ៤៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល អាចចោទប្រកាន់កូនក្តីខ្លួនថា ក្លែងឯកសារសាធារណៈបាន លុះត្រាតែកូនក្តីខ្លួនយកផែនទីដែលរដ្ឋតម្កល់ទុកនៅអង្គការសហប្រជាជាតិមកធ្វើការកែអក្សរ ឬគូសបន្ថែមក្រឡាការ៉ូ ប៉ុន្តែកូនក្តីខ្លួនគ្រាន់តែយកផែនទីដែលមាននៅក្នុង Google ប្រើជាផែនទីបោះពុម្ពថ្មី សាក្សីជំនាញទាំងពីរក៏បានទទួលស្គាល់ថា ផែនទីកូនក្តីខ្លួនប្រើជាផែនទីថ្មី ។ ឯកសារមួយចាត់ទុកជាឯកសារសាធារណៈ លុះត្រាតែឯកសារនោះចេញដោយអាជ្ញាធរសាធារណៈដូចជា ស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ និងតុលាការ ហើយឯកសារនោះត្រូវតែជាច្បាប់ដើម ហើយនិងនៅមានសុពលភាព ។ ឯកសារហ្វូតូកូពីពុំមែនជាឯកសារសាធារណៈទេ ។ ហេតុនេះ ផែនទីដែលកូនក្តីខ្លួនប្រើក្នុងការផ្សព្វផ្សាយតាមអ៊ិនធឺណែតនេះពុំមែនជាឯកសារសាធារណៈដែលមានតម្លៃផ្លូវច្បាប់ទេ ។ ចំពោះការចោទប្រកាន់ថា កូនក្តីខ្លួនផ្សព្វផ្សាយព័ត៌មានមិនពិត តំណាងអយ្យការបានសន្និដ្ឋានជារួម ដោយចោទថា កូនក្តីខ្លួនផ្សព្វផ្សាយព័ត៌មានមិនពិតដើម្បីទំលាក់កំហុសដល់រាជរដ្ឋាភិបាលពុំត្រឹមត្រូវទេ ព្រោះថាកូនក្តីខ្លួនគ្រាន់តែបានធ្វើការផ្សព្វផ្សាយពីផែនទី ដែលមានតំរុយបង្គោលព្រំដែនកម្ពុជា-វៀតណាម ដោយផ្អែកលើការស្រាវជ្រាវរបស់គាត់ប៉ុណ្ណោះ កូនក្តីខ្លួនជាតំណាងរាស្ត្រគាត់មានតួនាទីរក្សាបូរណភាពដែនដីពុំមានបំណងទំលាក់កំហុសទៅលើនរណាទេ គាត់គ្រាន់តែធ្វើជាកញ្ចក់ឆ្លុះបញ្ចាំងតែប៉ុណ្ណោះ អាចចោទប្រកាន់កូនក្តីខ្លួនបានពីបទផ្សព្វផ្សាយព័ត៌មានមិនពិត លុះត្រាតែបង្កើតគណៈកម្មការមួយ

ដែលមានសមាសភាពតុលាការ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងខ្លួនចុះទៅវាស់វែងជាក់ស្តែង បញ្ជាក់ជាមុនសិន បើពុំទាន់មានអ្វីបញ្ជាក់ផង ចោទប្រកាន់កូនក្តីខ្លួនបានដោយរបៀបណា ? ការចោទប្រកាន់ថា កូនក្តីខ្លួនបានប្រើទិន្នន័យពុំត្រឹមត្រូវពុំមែនទេ ទោះបីជាយក Datum WGS84 ទៅដាក់លើផែនទី Datum Indian 1960 ក្តីក៏ទទួលបានលទ្ធផលដូចគ្នា ស្ទើរតែត្រួតស៊ីគ្នា មានភស្តុតាងបញ្ជាក់ដូចអ្នកជំនាញលោក Régis Caloz បញ្ជាក់ក្នុងឯកសារស្រាប់នៅទំព័រទី១០ សូមបញ្ជាក់ថា លោក Caloz ជាអ្នកជំនាញឯករាជ្យ ។ តុលាការអាចឱ្យមានការតទល់រវាងអ្នកជំនាញរបស់រាជរដ្ឋាភិបាល និងអ្នកជំនាញឯករាជ្យនឹងអាចដឹងការពិតហើយ ។ តាមលោក Caloz ការប្រើ Datum Indian1960 ឬប្រើ Datum WGS84 គឺលទ្ធផលដូចគ្នា លទ្ធផលត្រួតស៊ីគ្នា ខុសគ្នាតែបន្តិចទេ ពុំមែន ខុសគ្នាដល់ទៅ ៥៣០ ម៉ែត្រ នោះទេ ។ ការចោទប្រកាន់ថា កូនក្តីខ្លួនផ្សាយព័ត៌មានមិនពិត ដោយ កូនក្តីខ្លួនផ្សាយឯកសារផែនទីបង្គោលព្រំដែនខុសនឹងទីតាំងជាក់ស្តែង សូមបញ្ជាក់ថា កូនក្តីខ្លួនពុំបានកំណត់ទីតាំងបង្គោលព្រំដែនថ្មីទេ កូនក្តីខ្លួនបានយកនិយាមការដែលវាស់វែងបានពីទីតាំងជាក់ស្តែង ស្នើឱ្យអ្នកជំនាញផែនទីដៅចំណុចតម្រុយបង្គោលព្រំដែនទាំងបួននៅលើផែនទីឱ្យបានជាក់លាក់ស្របតាមនិយាមការភូមិសាស្ត្រពិតប្រាកដ ។ កូនក្តីខ្លួនមិនមានគោលបំណងទំលាក់កំហុសដោយអសុទ្ធចិត្ត បំផ្លិចបំផ្លាញ ឬធ្វើឱ្យកើតកោលាហលដល់សន្តិសុខសាធារណៈទេ គឺកូនក្តីខ្លួនគ្រាន់តែចង់ការពារបូរណភាពទឹកដីខ្មែរប៉ុណ្ណោះ ។ ផែនទីដែលរដ្ឋាភិបាលកម្ពុជាបានតម្កល់ទុកនៅអង្គការសហប្រជាជាតិ ទៅហើយពុំអាចយកមកបានផង តើធ្វើយ៉ាងម៉េចកូនក្តីខ្លួនអាចទៅក្លែងផែនទីនោះបានទៅ ? តាមផែនទី និងឯកសារដែលកូនក្តីខ្លួនផ្សព្វផ្សាយគឺទីតាំងតម្រុយបង្គោលព្រំដែនលេខ ១៨៤ ១៨៥ ១៨៦ និងលេខ ១៨៧ គឺបោះនៅក្នុងទឹកដីខ្មែរ ។ ការចោទប្រកាន់របស់គណៈកម្មាធិការព្រំដែនថា កូនក្តីខ្លួនធ្វើការកំណត់ទីតាំងបង្គោលព្រំដែនមិនត្រឹមត្រូវ តើទីតាំងដែលត្រឹមត្រូវនៅត្រង់កន្លែងណា? ហើយមាននិយាមការប៉ុន្មាន ? នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០១០ ខ្លួនបានធ្វើលិខិតស្នើសុំឱ្យសាលាដំបូងរាជធានីភ្នំពេញ បង្កើតគណៈកម្មការចុះអង្កេត និងវាស់វែងរកនិយាមការទីតាំងជាក់ស្តែងនៃបង្គោលព្រំដែនកម្ពុជា និងវៀតណាម លេខ ១៨៤ ១៨៥ ១៨៦ និងលេខ ១៨៧ និង សុំឱ្យតុលាការ បង្គាប់ឱ្យដើមបណ្តឹងផ្តល់និយាមការត្រឹមត្រូវនៃបង្គោលព្រំដែនទាំងបួននេះ ដើម្បីទុកជាមូលដ្ឋានក្នុងការវិនិច្ឆ័យ ។ តែសាលាដំបូងរាជធានីភ្នំពេញមិនបានបង្កើតគណៈកម្មការចុះទៅវាស់វែងទេ ហើយក៏មិនបង្គាប់ឱ្យដើមបណ្តឹងផ្តល់និយាមការត្រឹមត្រូវនៃទីតាំងបង្គោលព្រំដែនកម្ពុជា-វៀតណាមទាំងបួននោះដែរ បែរជាបង្គាប់ឱ្យដើមបណ្តឹងពន្យល់បំភ្លឺពីនិយាមការត្រឹមត្រូវនៃទីតាំងបង្គោលព្រំដែនទាំងបួននោះទៅវិញ ហើយបានផ្តល់ការបកស្រាយចោទប្រកាន់កូនក្តីខ្លួនពីបទ ក្លែងផែនទីដែលរដ្ឋាភិបាលតម្កល់នៅអង្គការសហប្រជាជាតិ និងចោទថាបានផ្សព្វផ្សាយផែនទីមិនត្រឹមត្រូវ ផែនទីក្លែងក្លាយ ដោយបានកំណត់ទីតាំងបង្គោលព្រំដែនមិនត្រឹមត្រូវ ។ តាមបួងសួងរមកន្លែងកើតហេតុគូសដោយឈ្មោះ ស៊ិន ឈឿន ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៩

ដែលបានដាក់ជាសំអាងនៅសាលាដំបូងខេត្តស្វាយរៀង បង្ហាញថា ទីតាំងបង្គោលលេខ ១៨៥ មានចំងាយ ១០០ ម៉ែត្រពីទំនប់ក្រវ៉ាត់ព្រំដែន ។ តាមរបាយការណ៍ស្នងការខេត្តស្វាយរៀង ដែលមានអភិបាលខេត្តស្វាយរៀងចុះហត្ថលេខាផងនោះ បានបង្ហាញថា តម្រុយបង្គោលព្រំដែនលេខ ១៨៥ មាននិយាមការ E626271, N1209506 មានចំងាយ ៤៩០ម៉ែត្រពីវត្តអង្គរំដេញ ចំងាយ ១២០ម៉ែត្រ ពីទំនប់ព្រំដែនទិសខាងកើតត្រង់ចំងាយ ១៣០ ម៉ែត្រ ពីទំនប់ព្រំដែនទិសឦសានត្រង់ក្នុងចន្លោះតម្រុយទៅទំនប់ព្រំដែនជាដីដែលកម្ពុជាធ្លាប់គ្រប់គ្រងកន្លងមក ។ តាមប្លង់គូសដោយឈ្មោះ ស៊ិន ឈឿន កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៩ និងរបាយការណ៍នគរបាលខេត្តស្វាយរៀង បង្ហាញថា តម្រុយបង្គោលព្រំដែនលេខ១៨៥ បោះក្នុងទឹកដីកម្ពុជា ។ តាមមាត្រា ២ មាត្រា ៧៧ មាត្រា ៨០ មាត្រា ១២៨ និងមាត្រា ១២៩ នៃរដ្ឋធម្មនុញ្ញ ព្រមទាំងមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយសុំឱ្យតុលាការ មេត្តាវិនិច្ឆ័យសេចក្តីដោយឯករាជ្យមិនលំអៀង ។ ជាការសន្និដ្ឋានគឺ គ្មានបទល្មើស ក្លែងបន្លំអក្សរ សាធារណៈ គ្មានបទល្មើសផ្សព្វផ្សាយព័ត៌មានមិនពិត ដូចការចោទប្រកាន់ទេ ។ រឿងក្តីនេះជារឿង បច្ចេកទេសផែនទីសុទ្ធសាធ ហើយក៏ជារឿងនយោបាយដែរ មិនមែនជារឿងព្រហ្មទណ្ឌទេ សូមតុលាការសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់ ។

-ក្រោយពីបានស្តាប់អំណានដីកាបង្គាប់ឱ្យចាប់ខ្លួន

-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី

-ក្រោយពីបានអំណានឯកសារពាក់ព័ន្ធក្នុងសំណុំរឿង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីរាជរដ្ឋាភិបាល

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារភស្តុតាង

**-ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

## សំអាងហេតុ

-តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ១១៩០ ដ.ជ.រ. ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០១០ ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ បានបញ្ជូនជនជាប់ចោទឈ្មោះ សម រង្ស៊ី មកជំនុំជម្រះពីបទ **ការក្លែងបន្លំអក្សរក្នុងឯកសារសាធារណៈ និង ការផ្សាយព័ត៌មានមិនពិត** ប្រព្រឹត្តនៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា កាលពីខែ កុម្ភៈ ឆ្នាំ ២០១០ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៩ និងមាត្រា ៦២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។ មាត្រា ៤៩ ចែងថា : គ្រប់ជនជ្រើសតាំងដោយការបោះឆ្នោត គ្រប់អ្នករដ្ឋការស៊ីវិល ឬយោធា គ្រប់ភ្នាក់ងារ

ផ្លូវការរបស់ភាគីណាមួយ ក្នុងបណ្ដាភាគីខ្មែរ ទាំងបួននៃកិច្ចព្រមព្រៀងក្រុងប៉ារីស ឬរបស់គ្រប់គណបក្សនយោបាយដែលបានចុះក្នុងបញ្ជី អ្នកទទួលខុសត្រូវរបស់ភាគីណាមួយ ក្នុងបណ្ដាភាគីខ្មែរទាំងបួននៃកិច្ចព្រមព្រៀងក្រុងប៉ារីស ឬរបស់គ្រប់គណបក្សនយោបាយដែលបានចុះក្នុងបញ្ជី ដែលក្នុងការបំពេញមុខងាររបស់ខ្លួន បានប្រព្រឹត្តបទក្លែង ដោយក្លែងហត្ថលេខា ឬដោយលួចកែលិខិតផ្លូវការ កែអក្សរ ឬកែហត្ថលេខា ដោយសន្មតជនម្នាក់ថាជាជនម្នាក់ទៀត ដោយធ្វើអក្សរ ឬស៊កបញ្ចូលអក្សរលើបញ្ជី ឬលិខិតសាធារណៈទាំងនោះ អ្នកណាដែលបានប្រើប្រាស់ ដោយដឹងខ្លួននូវរបស់ក្លែងបន្លំអស់ទាំងនោះ នឹងត្រូវមានទោសឧក្រិដ្ឋពីបទក្លែងលិខិតសាធារណៈ ហើយត្រូវផ្តន្ទាទោសពី ៥ឆ្នាំ ទៅ ១៥ឆ្នាំ ។ មាត្រា ៦២ ចែងថា : ពេលណាមានការចុះផ្សាយ ការផ្សព្វផ្សាយ ឬការផ្សាយបន្តតាមមធ្យោបាយណាក៏ដោយនូវព័ត៌មានមិនពិត ព័ត៌មានប្រឌិត ព័ត៌មានក្លែងក្លាយ ឬដោយកុហក ទំលាក់កំហុសដោយអសុទ្ធចិត្តទៅលើជនទីបី ក្នុងបំណងបំផ្លិចបំផ្លាញ ធ្វើឱ្យកើតកោលាហលដល់សន្តិសុខសាធារណៈ នាយក ឬអ្នកទទួលខុសត្រូវផ្សេងទៀតនៃការផ្សាយ ឬអ្នកទទួលខុសត្រូវលើមធ្យោបាយគមនាគមន៍ឯទៀតដែលពាក់ព័ន្ធ ដែលបានសំរេចទទួលចុះផ្សាយ ផ្សព្វផ្សាយ ឬផ្សាយបន្តនូវព័ត៌មានទាំងនោះ នឹងត្រូវផ្តន្ទាទោសដាក់គុកពី ៦ខែ ទៅ៣ឆ្នាំ ហើយត្រូវពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬផ្តន្ទាទោសណាមួយនៃទោសទាំងពីរនេះក៏បាន ។

-តាមដីកាសន្និដ្ឋានស្ថាពរលេខ ១០៧១ អយឧ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០១០ និងដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ១១៩០ ដ.ជ.រ ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០១០ របស់ចៅក្រមស៊ើបសួរ បានធ្វើការចោទប្រកាន់លើជនជាប់ចោទឈ្មោះ **សម រង្ស៊ី** ពីបទ ការក្លែងបន្លំអក្សរក្នុងឯកសារសាធារណៈ និងការផ្សាយព័ត៌មានមិនពិត កាលពីខែកុម្ភៈ ឆ្នាំ ២០១០ ប៉ុន្តែតំណាងអយ្យការបានស្នើសុំកែប្រែកាលបរិច្ឆេទនៃការប្រព្រឹត្តបទល្មើសដោយជនជាប់ចោទ មកជាដើមឆ្នាំ ២០១០ វិញ។ ការស្នើសុំនេះជាការត្រឹមត្រូវហើយ ព្រោះថា ជនជាប់ចោទបានធ្វើបទសំភាសន៍ជាសម្លេងផ្ទាល់ នៅក្នុងកម្មវិធីពន្លឺភ្លើងទៀន នៅថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១០ ដែលជាអង្គហេតុមានបង្ហាញនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែរ។

-ជនជាប់ចោទឈ្មោះ **សម រង្ស៊ី** មានសាវតារគ្រប់គ្រាន់ ហើយត្រូវបានចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៣១២ តព្រ ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ២០១០។ អវត្តមានរបស់ជនជាប់ចោទពុំបានធ្វើឱ្យប៉ះពាល់ដល់នីតិវិធីជំនុំជម្រះក្តីឡើយ ដោយតុលាការអាចចេញសាលក្រមកំបាំងមុខបាន តាមមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-តាមឯកសារភស្តុតាងជាផែនទី (ឯកសារលេខ ១៨/១២ និងលេខ ១៨/៣) ដែលបានដាក់ជូនតុលាការ ដោយមេធាវីរាជរដ្ឋាភិបាល តាមពាក្យស្នើសុំដាក់ភស្តុតាងលេខ ០០៧/១០ អ.ក.ប.ច/ម.ធ.រ.ប. ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០១០ បង្ហាញឱ្យឃើញពីផែនទីដែលផ្សព្វផ្សាយ

ជាសាធារណៈដោយជនជាប់ចោទឈ្មោះ សម រង្ស៊ី ដែលមានកំណត់ពីតម្រុយបង្គោលព្រំដែនលេខ ១៨៤ លេខ ១៨៥ លេខ ១៨៦ និងលេខ ១៨៧ ស្ថិតនៅភូមិកោះក្បាន ហើយនៅអមសន្លឹកផែនទីនេះបញ្ជាក់ជាអក្សរអង់គ្លេស និងអក្សរខ្មែរថា **"នេះជាច្បាប់ចម្លងនៃផែនទីផ្លូវការដែលរាជរដ្ឋាភិបាលកម្ពុជាបាន យកទៅតម្កល់ទុកនៅអង្គការសហប្រជាជាតិកាលពីខែមីនា ឆ្នាំ ១៩៦៤"** ហើយនៅលើសន្លឹកផែនទី មានក្រឡាការ៉ូផងដែរ។ តាមលិខិតបំភ្លឺចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១០ របស់ជនជាប់ចោទដែលបានដាក់ជូនតុលាការ ជនជាប់ចោទពុំបានបដិសេធថា ខ្លួនពុំបានផ្សព្វផ្សាយឯកសារផែនទីនេះទេ។

-តាមចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ **ស៊ីន សុធានី** និងឈ្មោះ **អ៊ិត សុត្ថា** ក៏ដូចជាលិខិតលេខ ០២១ ០៥/១០ អ.ជ.ព.ដ ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១០ របស់គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន បានបង្ហាញឱ្យឃើញថា ផែនទីខាងលើដែលផ្សព្វផ្សាយដោយជនជាប់ចោទឈ្មោះ សម រង្ស៊ី ពុំមែនជាផែនទីដែលត្រូវបានដាក់តម្កល់នៅអង្គការសហប្រជាជាតិទេ ដោយមូលហេតុថា ផែនទីដែលបានតម្កល់នៅអង្គការសហប្រជាជាតិពុំមានក្រឡាការ៉ូ ចំណែកឯផែនទីដែលផ្សព្វផ្សាយដោយជនជាប់ចោទមានក្រឡាការ៉ូ។ ចំណុចនេះបញ្ជាក់ឱ្យឃើញថា ផែនទីដែលផ្សព្វផ្សាយដោយជនជាប់ចោទ មានលក្ខណៈខុសពីការពិត។ ការបំភ្លឺរបស់ជនជាប់ចោទចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១០ ដែលបញ្ជាក់ថាផែនទីទាំងអស់សុទ្ធតែមានក្រឡាការ៉ូដែលគេហៅថា graticule ក៏ត្រូវបានច្រានចោលដោយសាក្សីឈ្មោះ ស៊ីន សុធានី និងឈ្មោះ អ៊ិត សុត្ថា និងលិខិតរបស់គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន ដោយបានបញ្ជាក់ថា ផែនទីខ្នាត ១/១០០.០០០ ពុំមាន grid ដែលជាខ្សែបណ្តាញចតុរង្គមានខ្នាតរង្វាស់មានតម្លៃជាម៉ែត្រទេ មានតែបណ្តាញក្រឡាការ៉ូ graticule ដែលជាបណ្តាញខ្សែរយៈទទឹង និងខ្សែរយៈបណ្តោយមានខ្នាតរង្វាស់ប្រើគិតជាមុមប៉ុណ្ណោះ។ ការបំភ្លឺរបស់សាក្សីជំនាញ និង គណៈកម្មាធិការចម្រុះកិច្ចការព្រំដែនមានលក្ខណៈច្បាស់លាស់អាចឱ្យតុលាការទទួលស្គាល់បាន។

-តាមការបំភ្លឺរបស់សាក្សីឈ្មោះ ស៊ីន សុធានី និងឈ្មោះ អ៊ិត សុត្ថា ក៏ដូចជាលិខិតចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១០ របស់គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន បានបញ្ជាក់ថា ការកំណត់អំពីតម្រុយបង្គោលព្រំដែនលេខ ១៨៤ លេខ ១៨៥ លេខ ១៨៦ និងលេខ ១៨៧ នៅលើសន្លឹកផែនទីផ្សព្វផ្សាយដោយជនជាប់ចោទ ខុសពីទីតាំងពិតប្រាកដរបស់បង្គោលព្រំដែនកំណត់ដោយអ្នកបច្ចេកទេស ដោយសារតែជនជាប់ចោទបានយកទិន្នន័យទីតាំងបង្គោលព្រំដែនវាស់វែងដោយប្រើឧបករណ៍ GPS ដែលមានទិន្នន័យយោង WGS-84 មកដាក់លើផែនទីដែលមានទិន្នន័យយោង ឥណ្ឌា ១៩៦០ ដោយពុំបានធ្វើការបំលែងទិន្នន័យជាមុន ជាហេតុនាំឱ្យមានភាពលំអៀងខុសគ្នាប្រហែល ៥៣០ ម៉ែត្រ។ ចំណុចនេះ បង្ហាញឱ្យឃើញថា ផែនទីដែលផ្សព្វផ្សាយដោយជនជាប់ចោទបានកំណត់នូវទីតាំងតម្រុយបង្គោលព្រំដែនខុសពីទីតាំងពិតប្រាកដនៃបង្គោល។ ជនជាប់ចោទបាន

បដិសេធថាខ្លួនពុំបានកំណត់ទីតាំងបង្គោលព្រំដែនអ្វីណាមួយទេ គឺពុំត្រឹមត្រូវឡើយ ព្រោះថា តាមឯកសារផែនទី ដែលជនជាប់ចោទបានផ្សព្វផ្សាយជាសាធារណៈ បានបង្ហាញអំពីការដៅចំណុចទីតាំងតម្រុយបង្គោលយ៉ាងច្បាស់លាស់។ ការដែលជនជាប់ចោទ អះអាងតាមលិខិតបំភ្លឺរបស់ខ្លួនថា ខ្លួនគ្រាន់តែបានវាស់និយាមការទីតាំងតម្រុយបង្គោលព្រំដែនដែលបានបោះ យកទៅឱ្យអ្នកជំនាញវិជ្ជាជីវៈខាងផែនទី ដៅចំណុចតម្រុយបង្គោលព្រំដែនបួននៅលើផែនទីឱ្យបានជាក់លាក់ ស្របតាមនិយាមការភូមិសាស្ត្រពិតប្រាកដ គឺមានន័យគ្រប់គ្រាន់បញ្ជាក់ថា ជនជាប់ចោទបានរៀបចំឱ្យមានការដៅចំណុចតម្រុយបង្គោលព្រំដែននៅលើសន្លឹកផែនទី ដែលខ្លួនបានផ្សព្វផ្សាយជាសាធារណៈនោះ។

-ក្រៅពីនេះ តាមចម្លើយរបស់សាក្សីឈ្មោះ ស៊ីន សុធានី និងឈ្មោះ អ៊ិត សុត្ថា ក៏ដូចជាការបំភ្លឺបញ្ជាក់ពីគណៈកម្មាធិការចម្រុះកិច្ចការព្រំដែន បានបញ្ជាក់ថា ទីតាំងចំណុចបង្គោលលេខ ១៨៦ ជាទីតាំងដែលជនជាប់ចោទធ្វើការសន្មតដោយខ្លួនឯង ដែលក្រុមបច្ចេកទេសចម្រុះរបស់គណៈកម្មការព្រំដែនកម្ពុជា-វៀតណាម ពុំទាន់បានធ្វើការសិក្សាចំណុចនេះនៅឡើយ។ ដូចនេះ ការកំណត់ចំណុចទីតាំងតម្រុយបង្គោលលេខ ១៨៦ ដោយជនជាប់ចោទនៅលើឯកសារផែនទីដែលបានផ្សព្វផ្សាយ គឺជាការកំណត់ដោយឆន្ទៈឯកតោភាគីរបស់ជនជាប់ចោទ ដែលពុំមានសមត្ថកិច្ចក្នុងការកំណត់ទីតាំងតម្រុយបង្គោលព្រំដែនតាមច្បាប់ឡើយ។ ចំណែកឯសេចក្តីបំភ្លឺរបស់ជនជាប់ចោទចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១០ ដែលថា និយាមការភូមិសាស្ត្រពាក់ព័ន្ធដែលមាននៅលើដី ទទួលបានដោយមានជំនួយពីឧបករណ៍ GPS និងតាមការចង្អុលបង្ហាញពីអ្នកភូមិ និងប្រជាកសិករ បង្ហាញឱ្យឃើញថា ជនជាប់ចោទខ្លួនឯងពុំមានព័ត៌មានច្បាស់លាស់ជាក់លាក់ជាផ្លូវការពីទីតាំងតម្រុយបង្គោលព្រំដែនលេខ ១៨៦ ទេ តែបែរជាយកទិន្នន័យ ហើយដៅតម្រុយបង្គោលលេខ ១៨៦ នៅលើឯកសារផែនទីដែលខ្លួនផ្សព្វផ្សាយទៅវិញ។

-តាមលិខិតបំភ្លឺចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១០ ជនជាប់ចោទបានអះអាងថា ការប្រើប្រាស់និយាមការដែលមានទិន្នន័យយោងមិនដូចគ្នា នៅចុងបញ្ចប់មិនប៉ះពាល់លទ្ធផលទេ ដោយសំអាងទៅលើការពន្យល់របស់សាស្ត្រាចារ្យ Régis Caloz ប៉ុន្តែតាមការបំភ្លឺរបស់សាក្សីអ្នកជំនាញ និងការបំភ្លឺរបស់គណៈកម្មាធិការចម្រុះកិច្ចការព្រំដែនសុទ្ធតែ បានបញ្ជាក់យ៉ាងច្បាស់លាស់ថា បើមិនបានធ្វើការបំលែងទេ ចំណុចដែលទទួលបានពីការយកនិយាមការ WGS-84 មកប្រើក្នុងផែនទីដែលមានទិន្នន័យយោង Datum Indian 1960 មានភាពខុសគ្នាប្រហែល ៥៣០ ម៉ែត្រ។ ការអះអាងរបស់ជនជាប់ចោទដោយសំអាង ទៅលើការពន្យល់របស់សាស្ត្រាចារ្យម្នាក់ ពុំអាចជាមូលដ្ឋានឱ្យតុលាការជឿជាងការពន្យល់របស់អ្នកជំនាញ នៃគណៈកម្មាធិការចម្រុះកិច្ចការព្រំដែនឡើយ។

-ទោះបីជាជនជាប់ចោទអះអាងថា ការប្រើប្រាស់ទិន្នន័យយោងមួយណា ក៏ទទួលបានលទ្ធផលដូចគ្នានោះ ក៏ត្រូវច្រានចោលដោយសាក្សីជាអ្នកជំនាញ និង គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន ដែលបានបង្ហាញឱ្យឃើញពីទីតាំងតម្រុយបង្គោលព្រំដែនលេខ ១៨៤ លេខ ១៨៥ លេខ ១៨៦ និងលេខ ១៨៧ កំណត់ដោយប្រើទិន្នន័យយោងត្រឹមត្រូវ និងទីតាំងបង្គោលព្រំដែនលេខ ១៨៤ លេខ ១៨៥ លេខ ១៨៦ និងលេខ ១៨៧ ដែលជនជាប់ចោទបានផ្សព្វផ្សាយ គឺខុសគ្នា (ឯកសារលេខ ១៥/២ លេខ ៤៣/១ លេខ ៤៣/២ អំពីភាពខុសគ្នារវាងទីតាំងបង្គោលព្រំដែនលេខ ១៨៤ ១៨៥ ១៨៦ និង ១៨៧ តាមការវាស់វែងដោយលោក សម រង្ស៊ី (ដោយពុំបានបំលែងទិន្នន័យយោង Datum) និងទីតាំងបង្គោលរបស់គណៈកម្មការព្រំដែន ដែលភ្ជាប់មកជាមួយនឹងលិខិតលេខ ០២១ ០៥ /១០ អ.ជ.ព.ដ. ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១០ របស់គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន)។ ការបង្ហាញពីភាពខុសគ្នានេះ មានលក្ខណៈច្បាស់លាស់អាចឱ្យតុលាការជឿបាន។

-ការលើកឡើងរបស់មេធាវីការពារជនជាប់ចោទដែលទាមទារ ឱ្យមានគណៈកម្មការឯករាជ្យមួយ ដើម្បីធ្វើការវាស់វែងឱ្យដឹងការពិតនេះ ធ្លាប់ត្រូវបានចៅក្រមស៊ើបសួរសម្រេចបដិសេធតាមដីកាសម្រេចបដិសេធពាក្យស្នើសុំឱ្យបំពេញកិច្ចលេខ ៧៩៣៣ តព្រ ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០១០ ហើយសាលាឧទ្ធរណ៍ក៏បានសម្រេចតម្កល់ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរតាមសាលដីកាលេខ ៣៦ ញ ចុះថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០១០ ដោយសំអាងលើមូលហេតុថា ការបង្កើតគណៈកម្មការស៊ើបអង្កេត និងវាស់វែងព្រំដែន ពុំមែនជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរឡើយ គឺជាសមត្ថកិច្ចរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដែលបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៧៥ ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០០៥ និងជាស្ថាប័នមានសមត្ថកិច្ចផ្ដាច់មុខតែមួយគត់របស់រាជរដ្ឋាភិបាលក្នុងការធ្វើកិច្ចការព្រំដែននេះ។ ម្យ៉ាងទៀតការស្នើសុំឱ្យបំពេញកិច្ចនេះ មិនពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់ឡើយ។ ហេតុនេះ ការទាមទាររបស់មេធាវីការពារជនជាប់ចោទត្រង់ចំណុចនេះមិនមានមូលហេតុត្រឹមត្រូវ ឱ្យតុលាការទទួលស្គាល់ឡើយ។

-លើសពីនេះ សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទដែលទាមទារ ឱ្យមានការតទល់រវាងអ្នកជំនាញរបស់រាជរដ្ឋាភិបាល និងលោក Régis Caloz ទើបអាចដឹងការពិតថា ការប្រើទិន្នន័យយោង ឥណ្ឌូ ១៩៦០ និងការប្រើទិន្នន័យយោង WGS-84 នឹងផ្ដល់លទ្ធផលដូចគ្នា ឬខុសគ្នានោះ ជាការទាមទារដែលពុំមានមូលដ្ឋានត្រឹមត្រូវឡើយ ដោយហេតុថា ការបញ្ជាក់ដោយគណៈកម្មាធិការចម្រុះកិច្ចការព្រំដែន មានលក្ខណៈគ្រប់គ្រាន់ និងពេញលេញ សម្រាប់ឱ្យតុលាការធ្វើជាមូលដ្ឋាននៃការពិចារណាសម្រេចសេចក្ដី រីឯការអះអាងរបស់សាស្ត្រាចារ្យ Régis Caloz ជាទីសំអាងរបស់ជនជាប់ចោទ គ្រាន់តែជាការអះអាងរបស់បុគ្គលមួយរូបប៉ុណ្ណោះ។

-ដោយយោងទៅលើអង្គហេតុខាងលើ បង្ហាញឱ្យឃើញថា ជនជាប់ចោទបានលួចកែលិខិតផ្លូវការ គឺផែនទីនៃព្រះរាជាណាចក្រកម្ពុជា ដោយស៊កបញ្ចូលនូវលេខ អក្សរ សញ្ញា ដែលកំណត់ពីទីតាំងបង្គោលព្រំដែនលេខ ១៨៤ លេខ ១៨៥ លេខ ១៨៦ និងលេខ ១៨៧ នៅលើសន្លឹកផែនទីខុសពីការពិត ហើយយកទៅផ្សព្វផ្សាយជាសាធារណៈ ដើម្បីឱ្យគេជឿថា ទីតាំងតម្រុយបង្គោលដែលជនជាប់ចោទបានផ្សព្វផ្សាយ នោះជាទីតាំងតម្រុយបង្គោលពិតប្រាកដ ព្រមទាំងបន្ថែមក្រឡាការ៉ូនៅលើសន្លឹកផែនទីជនជាប់ចោទអះអាងថាមាន ក្រឡាការ៉ូ ដែលតាមពិតផែនទីនោះពុំមានក្រឡាការ៉ូ grid ទេ ។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទដែលថា អាចចោទប្រកាន់កូនក្តីខ្លួនពីបទក្លែងឯកសារសាធារណៈបាន លុះត្រាតែកូនក្តីខ្លួនយកផែនទីដែលតម្កល់ទុកនៅអង្គការសហប្រជាជាតិមកធ្វើការកែអក្សរ ឬគូសបន្ថែមក្រឡាការ៉ូ ឬកែខុសពីសភាពដើម ហើយយកទៅតម្កល់ទុកនៅអង្គការសហប្រជាជាតិវិញ គឺពុំត្រឹមត្រូវទេ ព្រោះថា បទល្មើសក្លែងបន្លំអក្សរក្នុងឯកសារសាធារណៈដែលមានចែងនៅមាត្រា ៤៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ពុំមែនសំដៅតែទៅលើការកែអក្សរ ឬគូសបន្ថែមនៅលើឯកសារច្បាប់ដើមនោះទេ។ មាត្រា ៤៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ពុំបានបញ្ជាក់ថា លុះត្រាតែកែអក្សរ ឬធ្វើអក្សរ ឬស៊កបញ្ចូលអក្សរក្នុងឯកសារច្បាប់ដើម ទើបចាត់ទុកជាបទល្មើសឡើយ។ ការបំភ្លៃខ្លឹមសារការពិតនៃលិខិត ឬ ឯកសារណាមួយ គឺជាការក្លែងបន្លំហើយ។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទដែលថា ឯកសារជាផែនទីដែលកូនក្តីខ្លួនយកមកប្រើគឺជាផែនទីដែលមាននៅក្នុង google ហើយកូនក្តីខ្លួនគ្រាន់តែយកឯកសារថតចម្លងមកប្រើ ពុំមែនជាឯកសារសាធារណៈ ដែលពុំមែនជាធាតុផ្សំនៃបទល្មើសចែងនៅមាត្រា ៤៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល គឺពុំត្រឹមត្រូវទេ ដោយហេតុថា លិខិតសាធារណៈ ឬឯកសារសាធារណៈដែលមានចែងនៅមាត្រា ៤៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ពុំសំដៅលើលិខិតសាធារណៈ ឬឯកសារសាធារណៈជាច្បាប់ដើមឡើយ។ ការដែលកែអក្សរ ឬគូសបន្ថែមនៅលើឯកសារ ឬលិខិតដែលជាលិខិត ឬឯកសារសាធារណៈ ទោះបីជាឯកសារច្បាប់ដើម ឬឯកសារថតចម្លង គឺជាធាតុផ្សំនៃបទល្មើស ការក្លែងបន្លំអក្សរក្នុងឯកសារសាធារណៈ តាមមាត្រា ៤៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ឱ្យតែឯកសារដែលបំភាន់នោះ គឺជាឯកសារ ឬលិខិតដែលត្រូវបានទទួលស្គាល់ថា ជាលិខិតដែលចេញដោយអាជ្ញាធរសាធារណៈជាការគ្រប់គ្រាន់ហើយ។

-ផែនទីនៃព្រះរាជាណាចក្រកម្ពុជាដែលតម្កល់នៅអង្គការសហប្រជាជាតិ មានលក្ខណៈពេញលេញជាឯកសារសាធារណៈ ឬលិខិតសាធារណៈតាមអត្ថន័យនៃមាត្រា ៤៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-តាមរយៈការបំភ្លឺចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១០ ជនជាប់ចោទ បានបង្ហាញយ៉ាងច្បាស់ពីចេតនារបស់ជនជាប់ចោទ ក្នុងការយកទិន្នន័យទីតាំងបង្គោលព្រំដែនវាស់វែងដោយប្រើឧបករណ៍ GPS ដែលមានទិន្នន័យយោង WGS-84 មកដាក់លើផែនទីខ្នាត ១/១០០.០០០ ដែលមានទិន្នន័យយោងឥណ្ឌូ ឆ្នាំ ១៩៦០ ព្រោះថា យោងតាមសេចក្តីបំភ្លឺរបស់គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១០ បានគូសបញ្ជាក់ថា បណ្តាផែនទីដែលបានផលិត និងប្រើប្រាស់ជាទូទៅនៅក្នុងស្រុកខ្មែរ មានការបញ្ជាក់ច្បាស់លាស់ពីទិន្នន័យយោង (Datum) ដើម្បីឱ្យអ្នកប្រើប្រាស់មានលទ្ធភាពប្រើប្រាស់ផែនទីនេះបានច្បាស់លាស់ និងមិនមានកំហុស។

-យោងតាមអង្គហេតុដូចបានរៀបរាប់ខាងលើ បានបង្ហាញឱ្យឃើញថាជនជាប់ចោទឈ្មោះ សម រង្ស៊ី មានចេតនាយកទិន្នន័យដែលវាស់វែងបានតាមឧបករណ៍ GPS ដែលមានទិន្នន័យយោង WGS-84 មកដាក់លើផែនទីដែលមានទិន្នន័យយោងឥណ្ឌូ ១៩៦០ ដោយពុំបានបំលែងទិន្នន័យពីទិន្នន័យយោង WGS-84 មកទិន្នន័យយោងឥណ្ឌូ ១៩៦០ ទេ ដោយជនជាប់ចោទបានដឹង ឬធ្វើជាមិនដឹងថា ការធ្វើយ៉ាងដូច្នេះនឹងនាំឱ្យមានលទ្ធផលខុសពីការពិត ទោះជាយ៉ាងណាក្តី ជនជាប់ចោទនៅតែប្រព្រឹត្តទៀត ដើម្បីទទួលបានលទ្ធផលតាមការចង់បានរបស់ខ្លួន ដោយទន្ទឹមនឹងនេះ ជនជាប់ចោទក៏ដឹងដែរថា ខ្លួនពុំមានសមត្ថកិច្ចតាមផ្លូវច្បាប់ក្នុងការដៅតម្រុយបង្គោលព្រំដែនទេ។ សកម្មភាពទាំងនេះបញ្ជាក់ឱ្យឃើញពីចេតនាទុច្ចរិតរបស់ជនជាប់ចោទ ក្នុងការបំភាន់នូវខ្លឹមសារការពិតនៃទីតាំងតម្រុយបង្គោលព្រំដែនលេខ ១៨៤ លេខ ១៨៥ លេខ ១៨៦ និងលេខ ១៨៧ នៅលើសន្លឹកផែនទី ដែលជនជាប់ចោទបានធ្វើការផ្សព្វផ្សាយជាសាធារណៈ។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការដែលនៅតែរក្សាការចោទប្រកាន់លើជនជាប់ចោទពីបទ ក្លែងបន្លំអក្សរក្នុងឯកសារសាធារណៈ មានលក្ខណៈត្រឹមត្រូវ។

-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទឈ្មោះ សម រង្ស៊ី ពីបទ **ក្លែងបន្លំអក្សរក្នុងឯកសារសាធារណៈ** ប្រព្រឹត្តនៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា កាលពីដើមឆ្នាំ ២០១០ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-តាមការសំភាសន៍ផ្ទាល់នៅក្នុងកម្មវិធីសម្លេងភ្លើងទៀន ក្រោមប្រធានបទ : **ភស្តុតាងនៃការរំលោភបំពានចូលមកលើដីខ្មែរពីសំណាក់ប្រទេសជិតខាងនៅតាមបណ្តោយព្រំដែន** ជនជាប់ចោទបានទទួលស្គាល់ថា ខ្លួនបានធ្វើការផ្សព្វផ្សាយឯកសារចំនួន ១៥ ទំព័រ ពាក់ព័ន្ធនឹងផែនទីព្រំដែនកម្ពុជា វៀតណាម។ តាមលិខិតបំភ្លឺរបស់ជនជាប់ចោទចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១០ ជនជាប់ចោទ ក៏បានទទួលស្គាល់ពីការបង្ហាញជាសាធារណៈនូវផែនទីដែលជាកម្មវត្ថុនៃការចោទប្រកាន់ដែរ។ តាមភស្តុតាងជាផែនទី (ឯកសារលេខ ១៨/១២ និងលេខ ១៨/៣) ដែលមេធាវីរាជរដ្ឋាភិបាលដាក់ជូនតុលាការ និងចម្លើយរបស់សាក្សីជំនាញទាំងពីររូបបង្ហាញថា ឯកសារផែនទី

នេះត្រូវបានផ្សព្វផ្សាយដោយជនជាប់ចោទតាមគេហទំព័រ WWW.SAMRAINSYPARTY.ORG ។ ហេតុនេះ ផែនទី (ឯកសារលេខ ១៨/១២ និងលេខ ១៨/៣) គឺជាឯកសារផែនទីដែលជនជាប់ចោទបានធ្វើការផ្សព្វផ្សាយតាមអ៊ីនធើណែត ។

-តាមការវិភាគទៅលើអង្គហេតុរៀបរាប់ខាងលើ ដោយយោងទៅតាមចម្លើយរបស់សាក្សីឈ្មោះ ស៊ីន សុធានី និងឈ្មោះ អ៊ិត សុត្ថា ព្រមទាំងការបំភ្លឺបញ្ជាក់ពីគណៈកម្មាធិការចម្រុះកិច្ចការព្រំដែន ឃើញថា ផែនទី (ឯកសារលេខ ១៨/១២ និងលេខ ១៨/៣) ជាឯកសារផែនទីដែលមានព័ត៌មានខុសពីការពិតត្រង់ចំណុច :

-ផែនទីនេះមានក្រឡាការ៉ូ grid ដែលជនជាប់ចោទអះអាងថា មាននៅលើផែនទីដែលព្រះរាជាណាចក្រកម្ពុជាបានតម្កល់នៅអង្គការសហប្រជាជាតិ ។

-ការដៅតម្រុយបង្គោលព្រំដែនលេខ ១៨៤ លេខ ១៨៥ លេខ ១៨៦ និងលេខ ១៨៧ ខុសពីទីតាំងតម្រុយបង្គោលព្រំដែនពិតប្រាកដ ។

-មេធាវីការពារជនជាប់ចោទបានសន្និដ្ឋានថា កូនក្តីខ្លួនមិនមានគោលបំណងទម្លាក់កំហុសដោយអសុទ្ធចិត្ត គ្មានបំណងបំផ្លិចបំផ្លាញ ឬធ្វើឱ្យកើតកោលាហលដល់សន្តិសុខសាធារណៈទេ ប៉ុន្តែតាមសម្លេងសំភាសន៍របស់ជនជាប់ចោទនៅក្នុងកម្មវិធីពន្លឺភ្លើងទៀនក្រោមប្រធានបទ **ភស្តុតាងនៃការរំលោភបំពានចូលមកលើដីខ្មែរពីសំណាក់ប្រទេសជិតខាងទៅតាមបណ្តោយព្រំដែន** នាំឱ្យតុលាការយល់ឃើញថា តាមរយៈការផ្សព្វផ្សាយនូវឯកសារផែនទី ជនជាប់ចោទមានបំណងចង់ឱ្យមតិជាតិ និងអន្តរជាតិយល់ថា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈគណៈកម្មាធិការចម្រុះកិច្ចការព្រំដែន កំពុងតែអនុញ្ញាតឱ្យមានការរំលោភបំពានពីសំណាក់ប្រទេសជិតខាង គឺសាធារណៈរដ្ឋសង្គមនិយមវៀតណាម ដោយបោះបង្គោលព្រំដែនរំលោភបំពានចូលក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រយោជន៍ដល់ប្រទេសវៀតណាម ។ តាមសម្លេងសំភាសន៍របស់ជនជាប់ចោទនៅក្នុងកម្មវិធីពន្លឺភ្លើងទៀន ជនជាប់ចោទបានបញ្ជាក់ថា : **ក្រោយពីបានយកទិន្នន័យដែលខ្លួនទទួលបានទៅដាក់លើផែនទីបារាំង និងផែនទីអាមេរិកាំង គឺបង្គោលត្រូវបានបោះនៅលើទឹកដីខ្មែរ ! អញ្ចឹងមានការរំលោភបូរណភាពទឹកដីកម្ពុជាហើយ ។ យើងត្រូវតែរួបរួមគ្នា ត្រូវតែប្រតិកម្ម ! ជារឿងប្រទេសជាតិយើងទាំងអស់គ្នា ។** ពាក្យសម្តីនេះបង្ហាញនូវអត្ថន័យថាជនជាប់ចោទមានបំណងចោទប្រកាន់ពីការប្រគល់ដីខ្មែរឱ្យទៅប្រទេសវៀតណាម ប៉ះពាល់ដល់បូរណភាពដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។ សកម្មភាពនេះបង្ហាញឱ្យឃើញពីចេតនារបស់ជនជាប់ចោទ ដែលទម្លាក់កំហុសទៅលើរាជរដ្ឋាភិបាលដែលកំពុងតែគ្រប់គ្រងប្រទេស ថាបានកាត់ទឹកដីឱ្យទៅប្រទេសវៀតណាម តាមរយៈការបោះតម្រុយបង្គោលព្រំដែនលេខ ១៨៤ លេខ ១៨៥ លេខ ១៨៦ និងលេខ ១៨៧ បង្វិតខ្សែបន្ទាត់ព្រំដែនចូលមកក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាជាប្រយោជន៍ដល់ប្រទេសវៀតណាម ។ ការទម្លាក់កំហុសនេះ ធ្វើឡើងដោយអសុទ្ធចិត្តពីសំណាក់

ជនជាប់ចោទ ដើម្បីទទួលបាននូវការចំណេញសម្រាប់គណបក្សរបស់ខ្លួន ក្នុងនាមជនជាប់ចោទជាអ្នកដឹកនាំគណបក្ស។ ម្យ៉ាងវិញទៀត ការផ្សព្វផ្សាយនូវឯកសារផែនទី (ឯកសារលេខ ១៨/១២ និងលេខ ១៨/៣) តាមគេហទំព័រ និងការសំភាសន៍ជាសម្លេងតាមវិទ្យុនៅក្នុងកម្មវិធីពន្លឺភ្លើងទៀន ដែលអាចផ្សព្វផ្សាយនៅទូទាំងប្រទេស និងជាអន្តរជាតិផងនោះ គឺបានធ្វើឱ្យមានការយល់ច្រឡំពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិថា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើកិច្ចការនាំឱ្យខូចប្រយោជន៍ជាតិ គឺធ្វើឱ្យបាត់បង់ទឹកដីរបស់ជាតិ។ អំពើនេះធ្វើឱ្យប៉ះពាល់កិត្តិយសរបស់រាជរដ្ឋាភិបាលជាលក្ខណៈប្រវត្តិសាស្ត្រ និងធ្ងន់ធ្ងរបំផុត។ លើសពីនេះទៀត ការផ្សាយព័ត៌មានមិនពិតទម្លាក់កំហុស លើរាជរដ្ឋាភិបាលថា បានធ្វើឱ្យបាត់បង់ទឹកដីខ្មែរ ជាព័ត៌មានរសើបអាចធ្វើឱ្យមានប្រតិកម្ម យ៉ាងខ្លាំងពីសំណាក់ប្រជាពលរដ្ឋដែលមានការភាន់ច្រឡំ អាចនាំឱ្យមានការប្រឆាំងដោយប្រើហិង្សា ដោយប្រការណាមួយ ដើម្បីការពារបូរណភាពទឹកដីរបស់ខ្លួន។ ចំណុចនេះសបញ្ជាក់ឱ្យឃើញថា ការផ្សាយព័ត៌មានមិនពិតដោយជនជាប់ចោទ អាចធ្វើឱ្យកើតកោលាហលដល់សន្តិសុខសាធារណៈ។ ភាពរសើបនៃបញ្ហាព្រំដែនត្រូវបានដឹងជាទូទៅ ហើយជនជាប់ចោទខ្លួនឯង ក៏មិនអាចថាមិនបានដឹង ពីបញ្ហានេះដែរ។

-ជារួមមក តាមការបង្ហាញខាងលើនាំឱ្យតុលាការយល់ឃើញថា ជនជាប់ចោទបានផ្សាយព័ត៌មានមិនពិត ដោយទម្លាក់កំហុសដោយអសុទ្ធចិត្តទៅលើរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងបំណងបំផ្លិចបំផ្លាញកិត្តិយសរបស់រាជរដ្ឋាភិបាល និង ធ្វើឱ្យកើតកោលាហលដល់សន្តិសុខសាធារណៈទៀតផង។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការដែលនៅតែរក្សាការចោទប្រកាន់លើជនជាប់ចោទពីបទ **ការផ្សាយព័ត៌មានមិនពិត** មានលក្ខណៈត្រឹមត្រូវ។

-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ **សម រង្ស៊ី** ពីបទ **ការផ្សាយព័ត៌មានមិនពិត** ប្រព្រឹត្តនៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា កាលពីដើមឆ្នាំ ២០១០ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៦២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទដែលបានលើកសំអាងលើមាត្រា ២ នៃរដ្ឋធម្មនុញ្ញ មាត្រា ៧៧ នៃរដ្ឋធម្មនុញ្ញ ដើម្បីបញ្ជាក់ថា ជនជាប់ចោទ ជាតំណាងរាស្ត្រក្នុងរដ្ឋសភា ជាតំណាងប្រជាជាតិខ្មែរទាំងមូល មានតួនាទីការពារបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហេតុនេះជនជាប់ចោទមានអភ័យឯកសិទ្ធិ មានកាតព្វកិច្ចការពារជាតិ ការពារទឹកដីជូនជាតិខ្មែរនោះ គឺពុំមានការពាក់ព័ន្ធនឹងអង្គហេតុនៃការចោទប្រកាន់ឡើយ ព្រោះថា អង្គហេតុដែលតុលាការបានទទួលមកជំនុំជម្រះតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ ពាក់ព័ន្ធនឹងការក្លែងបន្លំអក្សរក្នុងឯកសារសាធារណៈ និងការផ្សាយព័ត៌មានមិនពិត។ ជនជាប់ចោទដែលជាតំណាងរាស្ត្រក្នុង

រដ្ឋសភា មានអភ័យឯកសិទ្ធិ ក៏ត្រូវបានសភានៃព្រះរាជាណាចក្រកម្ពុជាបានដកអភ័យឯកសិទ្ធិរួចហើយ ដែលជាហេតុនាំឱ្យតុលាការអាចចាត់ការវិនិច្ឆ័យសេចក្តីលើជនជាប់ចោទបាន ។ ចំណែកឯតួនាទីរបស់ជនជាប់ចោទក្នុងនាមជាតំណាងរាស្ត្រ ជនជាប់ចោទត្រូវប្រើប្រាស់ក្នុងក្របខ័ណ្ឌដែលច្បាប់អនុញ្ញាត ហើយបើជនជាប់ចោទបានប្រព្រឹត្តបទល្មើស ហើយអភ័យឯកសិទ្ធិក៏ត្រូវបានដកទៀត តុលាការជាស្ថាប័នមានសមត្ថកិច្ចក្នុងការចាត់ការ ។ រីឯការលើកឡើងនូវមាត្រា ១២៨ មាត្រា ១២៩ នៃរដ្ឋធម្ម នុញ្ញ និងមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ពុំមានការពាក់ព័ន្ធ នឹងអង្គហេតុនៃការចោទប្រកាន់ ដែលតុលាការត្រូវលើកយកមកពិចារណាឡើយ ។

-ការលើកឡើងដោយមេធាវីការពារជនជាប់ចោទដែលថា តាមប្លង់រូមកន្លែងកើតហេតុ គូសដោយឈ្មោះ ស៊ិន ឈឿន កាលពីថ្ងៃទី ២៥ ខែតុលា ឆ្នាំ ២០០៩ និងតាមរបាយការណ៍ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០០៩ របស់ស្នងការនគរបាលខេត្តស្វាយរៀង តម្រុយបង្គោលព្រំដែនលេខ ១៨៥ ពិតជាបានបោះនៅក្នុងទឹកដីខ្មែរ ក្នុងដីស្រែប្រជារាស្ត្រខ្មែរ ប្រាកដមែន ពុំមានការពាក់ព័ន្ធនឹងអង្គហេតុនៃការចោទប្រកាន់ឡើយ ហេតុនេះតុលាការមិនលើកយកបញ្ហានេះមកពិចារណាឡើយ ។

-ម្យ៉ាងទៀត ការលើកឡើងរបស់មេធាវីការពារជនជាប់ចោទដែលថា ដើមបណ្តឹងជាស្ថាប័ននីតិប្រតិបត្តិ ជាស្ថាប័ននយោបាយ ជនជាប់ចោទជាប្រធានគណបក្សជំទាស់ ជាអ្នកនយោបាយ អង្គហេតុនៃវិវាទពាក់ព័ន្ធនឹងផែនទី និងការកំណត់បង្គោលព្រំដែន ជារឿងបូរណភាពទឹកដី ជារឿងនយោបាយ មិនមែនជារឿងព្រហ្មទណ្ឌទេ ក៏ពុំត្រឹមត្រូវដែរ ដោយហេតុថា អំពើរបស់ជនជាប់ចោទត្រូវនឹងធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ ដូចបានរៀបរាប់ខាងលើ ដែលមាត្រា ៤៩ និងមាត្រា ៦២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល តម្រូវឱ្យផ្តន្ទាទោស ។

-ជនជាប់ចោទជានីតិជន មានសមត្ថភាពគ្រប់គ្រាន់ក្នុងការយល់ដឹងពីអំពើប្រព្រឹត្តរបស់ខ្លួន អាចឱ្យទទួលខុសត្រូវព្រហ្មទណ្ឌបាន ហើយក៏ពុំមានសញ្ញាណាមួយបង្ហាញថាជនជាប់ចោទមានស្មារតីមិនប្រក្រតីនោះដែរ ។

-ជនជាប់ចោទបានប្រព្រឹត្តបទល្មើសពីរដែលជាបទល្មើសត្រួតគ្នា តាមមាត្រា ១៣៦ នៃក្រមព្រហ្មទណ្ឌ ហើយបទល្មើសទាំងពីរត្រូវទទួលទោសដាក់ពន្ធនាគារ ដែលជាទោសមានប្រភេទដូចគ្នា ។ ហេតុនេះតុលាការអនុវត្តគោលការណ៍ស្រូបទោសដែលមានចែងនៅមាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌ ។

-ជនជាប់ចោទបានប្រព្រឹត្តបទល្មើសដែល ធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈធ្ងន់ធ្ងរ ។

-អំពើរបស់ជនជាប់ចោទ បានធ្វើឱ្យប៉ះពាល់ដល់ទំនាក់ទំនងល្អរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម ធ្វើឱ្យខូចខាតដល់ជីវភាព សេដ្ឋកិច្ច និងភាពសុខសាន្តរបស់ប្រជាពលរដ្ឋ ។

-តាមសាលក្រមព្រហ្មទណ្ឌលេខ ០១ "ក" ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០១០ របស់សាលាដំបូងខេត្តស្វាយរៀង បានសម្រេចផ្តន្ទាទោសឈ្មោះ សម រង្ស៊ី ភេទប្រុស អាយុ ៦០ ឆ្នាំ ពីបទ ធ្វើឱ្យខូចខាតដោយចេតនា (ដកតំរុយបង្គោលព្រំដែនលេខ ១៨៥ កម្ពុជា-វៀតណាម) និងញុះញង់ឱ្យមានការរើសអើងជាតិសាសន៍ ប្រព្រឹត្តនៅភូមិកោះក្បានកណ្តាល ឃុំសំរោង ខេត្តស្វាយរៀង កាលពីថ្ងៃទី ០៥ ខែតុលា ឆ្នាំ ២០០៩។

-តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រសិនបើតុលាការប្រកាសផ្តន្ទាទោសដាក់ពន្ធនាគារ ១ ឆ្នាំ យ៉ាងតិច ដោយគ្មានការព្យួរទោសទេ តុលាការអាចចេញនៅក្នុងពេលសវនាការដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទដែលអវត្តមាន។ ជនជាប់ចោទឈ្មោះ **សម រង្ស៊ី** មិនមានវត្តមាននាពេលសវនាការនៅចំពោះមុខតុលាការទេ ទោះបីជាបានទទួលដំណឹងអំពីការកោះហៅឱ្យចូលសវនាការក៏ដោយ ហើយជនជាប់ចោទក៏ត្រូវបានរកឃើញថាមានពិរុទ្ធភាព ពីបទ **ក្លែងបន្លំអក្សរក្នុងឯកសារសាធារណៈ និងបទផ្សាយព័ត៌មានមិនពិត** ដែលតម្រូវឱ្យមានការផ្តន្ទាទោសរហូតដល់ ១៥ ឆ្នាំ។ ចំណុចនេះជាមូលហេតុគ្រប់គ្រាន់ ដើម្បីឱ្យតុលាការចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌបាន។

-នាពេលសវនាការ ក៏ដូចជានៅចំពោះមុខចៅក្រមស៊ើបសួរ លោក គី តិច ជាមេធាវីរាជរដ្ឋាភិបាលបានប្តឹងទាមទារសំណងនៃការខូចខាតចំនួន ១០០ ០០០ ០០០ រៀល (មួយរយលានរៀល) ដោយសំអាងថា អំពើរបស់ជនជាប់ចោទបានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងទៅលើកិត្តិយសរបស់រាជរដ្ឋាភិបាល។ យោងតាមទំហំនៃអំពើប្រព្រឹត្តរបស់ជនជាប់ចោទដែលមានផលប៉ះពាល់យ៉ាងធំធេងលើកិត្តិយសរបស់រាជរដ្ឋាភិបាលដែលជាដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងបញ្ហាព្រំដែន កម្ពុជា វៀតណាម តុលាការយល់ឃើញថា អំពើរបស់ជនជាប់ចោទបានបង្កនូវការខូចខាតយ៉ាងច្រើនដល់ដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះ តុលាការសម្រេចតាមភាពសមរម្យជាក់ស្តែង។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសឈ្មោះ **សម រង្ស៊ី** ភេទប្រុស អាយុ ៦០ ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល **១០ ឆ្នាំ (ដប់ឆ្នាំ)** និងពិន័យជាប្រាក់ចំនួន **៥ ០០០ ០០០ រៀល (ប្រាំលានរៀល)** ពីបទ **ការក្លែងបន្លំអក្សរក្នុងឯកសារសាធារណៈ និង ការផ្សាយព័ត៌មានមិនពិត** ប្រព្រឹត្តនៅរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា កាលពីដើម ឆ្នាំ ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៩ និងមាត្រា ៦២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

២-សម្រេចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ **សម រង្ស៊ី** តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។/

៣-បង្គាប់ឱ្យឈ្មោះ **សម រង្ស៊ី** បង់ប្រាក់សំណងនៃការខូចខាត និងជម្ងឺចិត្តឱ្យរាជរដ្ឋាភិបាល តំណាងដោយលោកមេធាវី **គី តិច** ចំនួន **៦០ ០០០ ០០០ រៀល (ហុកសិបលានរៀល)**។ ការទាមទារលើសពីនេះ ត្រូវច្រានចោល។

៤-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ២០១០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០១០ កំបាំងមុខជនជាប់ចោទ ចំពោះមុខមេធាវីការពារជនជាប់ចោទ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| | | | |
|---|---|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| **សុខ នី** | **យ៉ា សុខនៀង** | **ម៉ាំង ស៊ីណារ** | **កែ សាខន** |

---

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

កែ_សាខន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ , ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១០

ក្រឡាបញ្ជី

សុខ_នី